# អាងទឹកប្រេះបែក

ព្រះអង្គ ទូលបង្គំជឿ ព្រះអង្គ ទូលបង្គំជឿ
គ្រប់ទាំងអស់ អាចសំរេចបាន ព្រះអង្គអើយ ទូលបង្គំជឿ។

2 ចូរឲ្យយើងនៅតែឈរមួយភ្លែត និង ឱនក្បាលចុះ។ ព្រះអម្ចាស់យេស៊ូវ ទូលបង្គំយើងខ្ញុំព្យាយាមនៅក្នុងការ បន្ទាបខ្លួនដើម្បី បញ្ជាក់ទៅកាន់ទ្រង់ដោយការ សរសើរតំកើងដោយជំនឿ។ ហើយយើងអធិស្ឋានព្រះអម្ចាស់អើយ ឥឡូវនេះដែល ទ្រង់នៅតែបន្តកាច់នំប៉័ងជីវិតដល់ទូលបង្គំ ប្រទានឲ្យទូលបង្គំនូវអ្វី ដែលទូល បង្គំ រាល់គ្នាត្រូវការ ព្រះបន្ទូលទ្រង់។ ទូលបង្គំទូលសូមដោយនូវព្រះនាមព្រះយេស៊ូវ ។ អាមែន។

3 សូមអង្គុយចុះ។ ខ្ញុំប្រាកដ ច្បាស់ណាស់ បើខ្ញុំនិយាយគ្រប់ទាំងព្រះបន្ទូលទាំងអស់នូវពាក្យ "អាមែន" ឥឡូវ ដែលជាទីកោតសរសើរដល់ព្រះ នោះព្រះពរនៃព្រះជាម្ចាស់នៅតែគង់នៅក្នុងចំណោមអ្នករាល់គ្នានៅទីនេះ។

4 ខ្ញុំបានអង្គុយនៅព្រឹកនេះ និង ស្តាប់ជិតទៅនឹងកម្មវិធីដ៏រីករាយ ជាមួយការធ្វើ ទីបន្ទាល់ មានររបៀបខុសៗគ្នាដែលម្នាក់ៗបានបង្ហាញ។ ហើយ ស្តាប់អ្នកមកថ្មី បងប្អូនប្រុសមកពីបាបទីស្ទនៅទីនេះ ដែលបានមកសូមទោសសម្រាប់ការគិតដែលខុសបន្តិច។ ដូច្នេះ ខ្ញុំ—ខ្ញុំពិតជារីករាយណាស់ថ្មីៗជាមួយមនុស្សមួយ ចំនួនដែលមានភាពជាមនុស្សគ្រប់គ្រាន់ ឬ—ឬសុភាពបុរសគ្រប់គ្រាន់ ផងដែរ បើគាត់គិតថាគាត់មានកំហុស។ គាត់ពិតជាមិនមែនសុំទោសចំពោះខ្ញុំទេ វាមិនមែនជាខ្ញុំទេដែលគាត់សុំទោសចំពោះ គឺជាព្រះជាម្ចាស់វិញ។ ដូច្នេះ ខ្ញុំ—ខ្ញុំរីក រាយចំពោះការនោះណាស់ឃើញ។ ព្រះជាម្ចាស់ប្រទានពរដល់បងប្អូនប្រុសយើង និង បងប្អូនដែលអ្នកផ្សាយដំណឹងល្អ។

5 ខ្ញុំគឺជាបាបទីស្ទ អ្នកដឹងហើយ ខ្ញុំធ្លាប់ជាកម្មសិទ្ធ របស់ក្រុមជំនុំបាបទីស្ទដោយផ្ទាល់ខ្លួន។ ខ្ញុំជាសមាជិកនៅក្រុមជំនុំ បេសកជនបាបទីស្ទ។ ពេលខ្ញុំមកក្នុងចំណោមមនុស្ស ខ្ញុំដឹងថាអ្នកមានអារម្មណ៍បែបណា។ ខ្ញុំមានអារម្មណ៍ដូចគ្នាដូចជាពេញដោយអ្វីមួយ ខ្ញុំ—ខ្ញុំមិនដឹង។

6 ខ្ញុំចងចាំពីបទពិសោធន៍ដំបូងរបស់ខ្ញុំ នៃការជួបជាមួយពួកពេនតេកុស្ត នៅ ដូវ៉ាជីអេក រដ្ឋមីស៊ីកូ...ខ្ញុំសូមទោស ខ្ញុំបានទៅដូវ៉ាជីអេក ដើម្បីធ្វើដំណើរស្ទូចត្រី ហើយចេញពី ដូវ៉ាជីអេក ទៅ អិនឌៀអាយណា។ ហើយខ្ញុំបានឃើញព្រះនាម នៃ "ព្រះយេស៊ូវ" លើរថយន្តនិងអ្វីៗទាំងអស់ ហើយ ខ្ញុំស្តាប់កម្មវិធីរបស់គេនៅថ្ងៃ នោះ។ ហើយ ថ្ងៃបន្ទាប់គេស្នើរឲ្យខ្ញុំឡើងទៅវេទិកា ដើម្បីនិយាយពាក្យខ្លះៗ ហើយ ខ្ញុំក៏បានធ្វើ។ ហើយ...គេសួរខ្ញុំថាតើខ្ញុំមកពីក្រុមជំនុំណា និង ខ្ញុំប្រាប់គេថា ខ្ញុំមក ពីបាបទីស្ត។

7 ហើយនៅយប់នោះ គេមានបុរសជនជាតិស្បែកខ្មៅម្នាក់ ជាអ្នកអធិប្បាយ គាត់នោះ មានអាយុ៨០ឆ្នាំហើយ ដោយគាត់បានឡើងទៅវេទិកា។ ជាមិត្តចាស់ ពួកគេស្ទើរតែនាំគាត់ចេញផង។ គាត់ជាម្នាក់ក្នុងចំណោម នៃអ្នកពាក់អាវធំ ព័ន្ធកិច្ចពីលើ ពណ៌សំពត់កាំម្វី និង មានជាយឆោមសត្វពណ៌សជុំវិញ។ ហើយ ខ្ញុំគិតថា "អ្នកដែលនៅទីនេះ ជាអ្នកទេវវិទូ ជាមនុស្សអស្ចារ្យ ហេតុអ្វីបានជា គេប្រគល់កម្មវិធីឲ្យទៅមិត្តដែលជរាបែបនោះ? ល្អ ល្អ បុរសជរាគួរតែមានកៅអី នៅកន្លែងណាមួយ អង្គុយនៅទីនោះ។"

8 ពួកគេអធិប្បាយនៅថ្ងៃនោះ អំពីព្រះយេស៊ូវ បានធ្វើនៅលើផែនដី។ ប៉ុន្តែ គាត់ យកអត្ថបទគាត់មក ខ្ញុំជឿថាវានៅក្នុង គម្ពីរយ៉ូប...៧:២០ ខ្ញុំមិនច្បាស់ដែរ ប្រហែលខគម្ពីរហ្នឹង។ ទោះជាយ៉ាងណា នេះគ្រាន់តែជាការដកស្រង់ប៉ុណ្ណោះ មាន ខ្លះនៃខគម្ពីរ "តើអ្នកនៅឯណាពេលយើងដាក់គ្រឹះផែនដីចុះ ពេលតារាពេលព្រឹករះ ឡើងទាំង អស់គ្នានិងបុត្ររបស់ព្រះជាម្ចាស់ស្រែកឡើង ដោយអំណរ?" ហើយ គាត់និយាយ អ្វីដែលមាននៅស្ថានសួគ៌ កាលបើគេនិយាយអ្វីដែលកើតមាននៅ ផែនដី។

9 ហើយ ប្រហែល៥នាទីមុនចាប់ផ្តើមអធិប្បាយ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ប៉ះនឹងគាត់ ហើយគាត់លោតឡើងលើកម្រាល និងចុចកែងជើងផ្គុំគ្នា។ ខ្ញុំអើយ មានធ្លាច្រើនណាស់វាស្ទើរតែពាក់កណ្តាលវេទិកាហើយគាត់ដើរចេញទៅ និយាយ "អ្នកមិនមានធ្លាគ្រប់គ្រាន់នៅទីនេះសម្រាប់ខ្ញុំដើម្បី អធិប្បាយឡើយ។"

10 ការពិត ខ្ញុំប្រហែលជាអាយុម្ភៃឆ្នាំ។ ខ្ញុំគិតថា "ប្រសិន—បើ នោះជាការ កើតឡើងចំពោះបុរសជរា តើវានឹងកើតមានចំពោះខ្ញុំយ៉ាងណា"? ដូច្នេះឃើញទេ?

11 តំណាងឲ្យការរក្សាអ្វីៗ ឲ្យមានសណ្ដាប់ធ្នាប់ សម្រាប់បងប្អូនថ្មីរបស់យើង ដែលយើងពិតជាស្វាគមន៍ពួកគេមកក្នុងការប្រកបគ្នារបស់យើង។ ខ្ញុំឃើញ ខ្ញុំជឿ ថាពួកគេបានចាប់អារម្មណ៍លើសពីសង្ឃអង្គុយនៅទីនេះខ្ញុំគិតថាប្រភេទ អៀឡង់ ជាមនុស្សរបស់ខ្ញុំដែលពួកគេជាកាតូលិក។ ហើយមានប្ដីប្រពន្ធមួយទៀត ជាអ្នកបាបទីស្ទតែខុសគ្នា។ អ្នកប្រហែលមានការច្របូកច្របល់បន្តិចមួយស្របក់។ ខ្ញុំឮ បងប្អូនម្នាក់និយាយពីរឿងនោះប៉ុន្តែខ្ញុំគិតថាខ្ញុំនឹងព្យាយាមបង្ហាញ។ នៅពេលដែល ប្អូនប្រុស សាកាវៀន...បន្ទាប់ពីបាននិយាយនៅទីនេះ គាត់ទទួលបានពោពេញដោយអំណរ ពីការដឹងនៃការយាងមករបស់ព្រះអម្ចាស់កាន់តែកៀកគាត់—គាត់ និយាយជាភាសាមិនស្គាល់ដល់យើង។ ហើយយើងមានអ្នកបកប្រែ ផ្ដល់ការបកប្រែដល់យើងដែរ។ ដែលខគម្ពីរ និយាយ "បើគ្មានអ្នកបកប្រែទេចូរឲ្យគេមានសេចក្ដីសុខសាន្តរបស់គេចុះ" ប៉ុន្តែបើ—បើពួកគេ និយាយភាសាដទៃបន្ទាប់មកបកប្រែវា វានិងក្លាយជាការទស្សន៍ទាយ។ ដូច្នេះមានការច្របូកច្របល់បន្តិច—គឺពីរនាក់និយាយក្នុងពេលតែមួយ។ ឥឡូវនេះមិនមានការច្រឡំទៀតទេ មើលពីព្រោះ ម្នាក់នៃពួកគេផ្ដល់ការបកប្រែ និងម្នាក់ទៀត ធ្វើការថ្លែងទំនាយ។ ឃើញ? ដូច្នេះ នោះគឺ...

12 ខ្ញុំគិតថា ខ្ញុំគួរឲ្យបងប្អូនរបស់យើងបានយល់ បើពួកគេមិនយល់ ពីព្រោះម្នាក់ក្នុងចំណោមពួកគេបកប្រែយ៉ាងត្រឹមត្រូវ...តើអ្នកកត់សម្គាល់ថាពេលវេលាមានកំណត់សំរាប់ម្នាក់ៗឬទេ? ហើយ ម្នាក់ទៀតបានពេញខ្លួនគាត់ ដោយវិញ្ញាណរបស់ព្រះកំពុងថ្លែងទំនាយតាមរយៈម្នាក់ កំពុងបកប្រែ ម្នាក់ទៀតនឹងផ្ដល់ការបកប្រែ។ ដូច្នេះប្រហែលជាច្បាស់ ដែលអ្នក...យើងមិនមែនជា...អ្វីមួយចំពោះគំនិតធម្មជាតិ...ដូចជាបងប្អូនប្រុសម្នាក់បានធ្វើការសូមទោសនៅព្រឹកនេះ។ វាជាការយល់ ច្រឡំបន្តិច ដល់មនុស្សដែលមិនយល់។ ប៉ុន្តែអស់អ្នកដែលនៅជា ទាហាន ជើង ចាស់នៃសមរភូមិ ដែលយើងកំពុងតែនៅ ហេតុអ្វីយើងអាចយល់ ពីអ្វីទាំងអស់ នេះបាន។ ដូច្នេះខ្ញុំគ្រាន់តែគិតថា ខ្ញុំនិយាយខ្លះពីវា ថាវាជាការត្រឹមត្រូវ។

13 ឥឡូវខ្ញុំ—ខ្ញុំដឹងថាមិនមែនជាកន្លែង ដែលត្រូវនិយាយរឿងនេះ។ ប៉ុន្តែក្នុងសភាពបែបនេះ គ្រប់គ្នាគួរតែស្ដាប់រឿងតូចមួយសិនខ្ញុំ...អ្នកដឹងថា មិត្តម្នាក់នោះនិយាយថាបុរសជនជាតិស្បែកខ្មៅជរានិយាយ "អ្នកមិនមានទីធ្លាល្មមគ្រប់គ្រាន់

នឹងខ្ញុំ អធិប្បាយ ឡើយ″ អ្នកមិនមាន *ពេលវេលា* គ្រប់គ្រាន់ សម្រាប់ខ្ញុំអធិប្បាយ ឡើយ។ [ក្រុមជំនុំសាទរ—Ed] ។ សម្លេងយូរ។

14 បុរសនោះនិយាយថ្ងៃមួយ និយាយថា ‶អ្នកដឹកនាំឡើងមក គាត់ជាគ្រូគង្វាល២០ឆ្នាំហើយ។ ហើយគាត់អធិប្បាយត្រឹមតែ៣០នាទី រៀងរាល់ព្រឹកថ្ងៃអាទិត្យនីមួយៗនៅព្រះវិហារនេះ″ ហើយ គាត់និយាយថា ‶នៅព្រឹកថ្ងៃអាទិត្យនេះ គាត់ អធិប្បាយ៣ម៉ោង។″

15 ហើយ ដូច្នេះ ក្រុមប្រឹក្សាចាស់ទុំ ហៅគាត់ចូលក្នុងនិង និយាយ ‶គ្រូគង្វាលយើងពិតជារីករាយជាមួយអ្នកណាស់។″ និយាយ ‶យើងតែងដឹង—ថាអ្នក ឈរដើម្បីតាំងនៅសម្រាប់ព្រះគម្ពីរនិងសិទ្ធរបស់វា។″ ហើយនិយាយ ‶ហើយ អ្នក តែងនិយាយកែតម្រង់យើងដើម្បីបានបរិសុទ្ធនៅចំពោះមុខព្រះជាម្ចាស់។ ហើយ យើងពិតជាសាទរជាមួយអ្នកហើយ យើងជឿថាអ្នកជា អ្នកបម្រើរបស់ព្រះជា ម្ចាស់។ ហើយយើងពិតជារីករាយជាមួយសារនៅព្រឹកនេះដែរ។ ប៉ុន្តែ″ និយាយ ‶មានរឿងមួយដែលយើងចង់សួរដល់អ្នក″ និយាយ ‶យើងឲ្យពេលអ្នក ជាចាស់ទុំ″ និយាយ ‶រៀងរាល់ព្រឹកថ្ងៃអាទិត្យអ្នកអធិប្បាយត្រឹមតែ៣០នាទីតែថ្ងៃនេះ អធិប្បាយ បីម៉ោង″ និយាយ‶ឥឡូវចងចាំយើងរីករាយជាមួយគ្រប់ទាំងចង្វាក់របស់វា។ វាពិត ប្រាកដ″ ធ្វើឲ្យមនុស្សចាស់ៗមានអារម្មណ៍ល្អ អ្នកដឹងទេ។

16 គាត់និយាយ ‶ល្អ បងប្អូនអើយ ខ្ញុំនឹងប្រាប់អ្នកថាវាជាយ៉ាងណា″ និយាយ ‶រៀងរាល់ព្រឹកពេលខ្ញុំទៅ…ខ្ញុំត្រូវបានហៅទៅលើវេទិកា″ និយាយ ‶ខ្ញុំដាក់ស្ករគ្រាប់មួយគ្រាប់ក្នុងមាត់″ គាត់បន្ត ‶គ្រាន់តែជញ្ជក់វា″ និងនិយាយ ‶ពេលស្ករគ្រាប់បានអស់″ គាត់បន្ថែមថា‶វាមានរយៈពេលតែ៣០នាទី″ និងនិយាយ‶ដូច្នេះ ខ្ញុំបញ្ចប់ការអធិប្បាយ។″ គាត់និយាយ ‶អ្នកដឹងទេ ព្រឹកនេះ ខ្ញុំគិតថាខ្ញុំលើសម៉ោងបន្តិច។ ខ្ញុំស្ដោះវាចេញ ខ្ញុំមានលេវក្នុងមាត់ខ្ញុំ″ [ក្រុមជំនុំសើច—Ed]។

17 ខ្ញុំនឹងមិនដាក់អ្វីទៅក្នុងឡើយ ដូច្នេះ យើងសង្ឃឹមថា យើងមិនមានលេវក្នុងហោប៉ៅឡើយ។ ប៉ុន្តែយើង…ខ្ញុំសង្ឃឹមថាមិនមានពាក្យអាក្រក់ឡើយ។ ប៉ុន្តែខ្ញុំគ្រាន់តែ…អ្នកដឹងទេ សូម្បីតែព្រះជាម្ចាស់ក៏មានកំប្លែងស្ងួតដែរ អ្នកដឹងទេ។

18 ដូច្នេះយើងអរគុណដែលអ្នកបានមកទីនេះនិងមានពេលវេលានេះដើម្បីប្រកបគ្នានិង—និងជាមួយអភ័យឯកសិទ្ធយ៉ាងពិសេស ដើម្បីកាច់នំប៉័ងជីវិតម្ដងទៀតក្នុងរបៀបធម្មតាតូចមួយរបស់ខ្ញុំ។ ខ្ញុំដឹង ជាទេវវិទូម្នាក់ ពេលបុរសម្នាក់នោះ

និយាយនៅទីនោះកាលពីយប់មិញដែលគាត់ មកពីអង់គ្លេសខ្ញុំមិនចូលចិត្តឈរនៅ ពីក្រោយមនុស្សបែបនោះ ជាមួយការសិក្សារបស់ខ្ញុំត្រឹមតែថ្នាក់ទី—ប្រាំពីរ។ ប៉ុន្តែខ្ញុំសង្ឃឹមថាព្រះជាម្ចាស់នឹងបកស្រាយដល់អ្នក ពីន័យដែលមាននៅ ក្នុងចិត្តរបស់ខ្ញុំ។ ឃើញ? បើពាក្យខ្ញុំមិនត្រឹមត្រូវ ការផ្តោតរបស់ខ្ញុំ ខ្ញុំ—ខ្ញុំទុកចិត្ត ។

19 ឥឡូវចូរឲ្យយើងអានខគម្ពីរ។ មានមនុស្សជាច្រើន ចូលចិត្តអានតាមក្រោយ។ ខ្ញុំនឹងអាននៅព្រឹកនេះ សម្រាប់ពីរបីដង ពីកណ្ឌយេរេមា ព្យាការី ជំពូក២ ហើយ ខ្ញុំនឹងចាប់ផ្តើមឥឡូវចាប់ពីខមួយ។

*ព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកដល់ខ្ញុំថា*

*ចូរទៅចុះ ហើយស្រែកដាក់ត្រចៀក ពួកក្រុងយេរូសាឡិមថា ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលដូច្នេះ គឺអញនឹកចាំពីឯងកាលនៅក្មេង ដែលឯងមានចិត្តគួចចំពោះអញ ហើយពីសេចក្តីស្រឡាញ់របស់ឯង កាលទើបនឹងបានគ្នា គឺដែលឯងបានដើរតាមអញ នៅក្នុងទីរហោស្ថាន ជាកន្លែងដែលឥតមានអ្នកណាសាបព្រោះឡើយ។*

*គ្រានោះ អ៊ីស្រាអែលជាពួកបរិសុទ្ធដល់ព្រះយេហូវ៉ា ជាផលដំបូងនៃសេចក្តី ចំរើនរបស់ទ្រង់ ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា អស់អ្នកណាដែលស៊ីបង្ខិនគេ នោះនឹងត្រូវមានទោស សេចក្តីអាក្រក់នឹងមកគ្របលើអ្នកនោះ។*

*ឱពួកវង្សរបស់យ៉ាកុប និងអស់ទាំងគ្រួសារនៃពួកអ៊ីស្រាអែលអើយ ចូរស្តាប់ព្រះបន្ទូលនៃព្រះយេហូវ៉ាចុះ*

*ទ្រង់មានព្រះបន្ទូលសួរថា ពួកឰយុកោរបស់ឯងរាល់គ្នា បានឃើញមាន សេចក្តីទុច្ចរិតយ៉ាងណានៅក្នុងអញ បានជាគេថយទៅឆ្ងាយពីអញដូច្នេះ ព្រមទាំងប្រព្រឹត្តតាមសេចក្តីឥតប្រយោជន៍ ហើយក៏ទៅជាឥតប្រយោជន៍គ្រប់គ្នាផង*

*គេក៏មិនបានសួរថា ព្រះយេហូវ៉ាដែលនាំយើងរាល់គ្នា ឡើងចេញពីស្រុកអេស៊ីព្ទមក ហើយបាននាំ យើងដើរកាត់ទីរហោ ស្ថាន ជាកន្លែងដែលមានសុទ្ធតែវាលខ្សាច់ និងជង្ហុក គឺជាទីមានតែដីហួតហែង និង*

*ម្លប់នៃសេចក្ដីស្លាប់ទទេ ជាកន្លែងដែលឥតមានមនុស្សដើរកាត់ ឬមនុស្សណាអាស្រ័យនៅឡើយ...តើទ្រង់នៅឯណា?*

*អញក៏បាននាំឯងរាល់គ្នាចូលទៅក្នុងស្រុកដ៏សំបូរ ដើម្បីឲ្យបានបរិភោគផល និងរបស់ល្អនៃស្រុកនោះ ប៉ុន្តែកាលឯងរាល់គ្នាបានចូលទៅហើយ នោះបានធ្វើឲ្យស្រុកអញទៅជាស្មោក គ្រោក ហើយឲ្យមរដករបស់អញ បានត្រឡប់ជាទីស្អប់ខ្ពើមវិញ។*

*ពួកសង្ឃក៏មិនបានសួរថា តើព្រះយេហូវ៉ាទ្រង់គង់នៅឯណាដែរ គឺពួកអ្នកដែលកាន់ប្រើក្រឹត្យវិន័យ គេមិនបានស្គាល់អញទេ ពួកគ្រប់គ្រងបានប្រព្រឹត្តរំលងនឹងអញ ហើយពួកហោរាបានទាយ ដោយព្រះបាលផង គេបានដើរតាមតែរបស់ដែលឥតមានប្រយោជន៍អ្វីសោះ។*

*ហេតុដូច្នេះ ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា អញនឹង...តវ៉ានឹងឯងរាល់គ្នាទៀត ហើយនឹងកូនចៅរបស់ឯងតទៅដែរ។*

*ដ្បិត...មានតែឆ្លងទៅឯកោះទាំងប៉ុន្មានរបស់ពួកគីទីមមើល ហើយចាត់គេទៅឯស្រុកកេដារ ឲ្យពិចារណាយ៉ាងអស់ពីចិត្ត នោះនឹងឃើញបើដែលមានអ្វីឲ្យដូចឬទេ ។*

*តើដែលមានសាសន៍ណា ផ្លាស់ព្រះរបស់ខ្លួន ដែលមិន...មែនជាព្រះផង ឬទេ តែរាស្ត្ររបស់អញបានដូរព្រះដ៏ជាសិរីល្អរបស់ខ្លួន ឲ្យបានតែរបស់ដែលឥតមានប្រយោជន៍វិញ។*

*ព្រះយេហូវ៉ាទ្រង់ព្រះបន្ទូលថា ឱផ្ទៃមេឃអើយ ចូរឲ្យនឹកប្លែកពីដំណើរនេះហើយឲ្យភ័យ...សម្បើមចុះ ត្រូវឲ្យមានចិត្តត្រមោចនៅ ។*

*ដ្បិតរាស្ត្រអញបាន ប្រព្រឹត្តអំពើអាក្រក់២យ៉ាង គឺបានទាំងបោះបង់ចោលអញ ដែលជាក្បាលទឹករស់ ហើយបានដាប់ធ្វើអាងវិញជាអាងប្រេះបែក ដែលទុកទឹកមិនបានផង។*

[20] សូមឲ្យព្រះអម្ចាស់ បន្ថែមព្រះពរទ្រង់ ដល់អ្នកអានព្រះបន្ទូលទ្រង់។ ខ្ញុំចង់ ឲ្យ—ឲ្យយកអត្ថបទនោះ ជា *អាងទឹកប្រេះបែក*។

21 ពេលបានអានក្នុងខគម្ពីរនេះ នៅព្រឹកនេះ ដែលអស់ទាំងខគម្ពីរត្រូវបានផ្តល់តាមរយៈការបណ្តាលមក។ យើងមកក្នុងដំណាក់ព្រះអម្ចាស់ សម្រាប់ការកែប្រែពីការយល់ដឹង។ ហើយ ជួនកាលយើងឃើញ...រឿងតូចមួយនៅក្នុងរបៀបនេះ។

22 ដូចជាទាហានម្នាក់នេះ ខណៈពេលកន្លងទៅ បាននិយាយមកកាន់យើង ហើយនិយាយពីអ្វីមួយជាក់លាក់ដែលប្រហែលជាប្រទេសផ្សេងទៀត មានមីស៊ីលពិតឬ—ឬអ្វីមួយក្នុងគំនិត ហើយយើងត្រូវស្វែងរកអ្វីមួយដើម្បីប្រតិកម្មក្នុង—ក្នុងយុទ្ធសាស្ត្រទាហាន។

23 ជាការពិត ដូចគ្នាអ្វីដែលកើតឡើងក្នុងព្រះវិហារ ក្នុងក្រុមជំនុំ ដែលមនុស្សកំពុងអធិប្បាយ ឬបើគាត់ជាអ្នកផ្សាយដំណឹងល្អក្នុងទីលាន។ ពេលគាត់ឃើញការងើបឡើង និង អ្វីមួយដែលចាប់ផ្តើម បន្តភាពក្មេងខ្ចីរបស់វា ឬអ្វីក៏ដោយ វាគឺបុរសនោះហើយបើសិនជាគាត់ជាអ្នកបម្រើរបស់ព្រះមែន ហើយបិទនៅរឿងទាំង អស់ នោះឲ្យនៅឆ្ងាយពីគំនិតរបស់មនុស្សដែលពួកគេនៅកាន់តែ ឆ្ងាយពីវា។ ហើយយើងមិនចង់ឲ្យរឿងនោះកើតឡើង ដល់យើងនៅក្នុងទីតាំងបែបនោះទេ។

24 ឥឡូវក្នុងសម័យយេរេមានៅទីនេះ ការថ្លែងទំនាយរបស់គាត់ មានរយៈពេល៦០ឆ្នាំទៅហើយ តាំងពីមរណៈភាពរបស់—អេសាយ—អេសាយ។ ហើយ ពួកគេមានរយៈពេលប្រមាណ៦០ឆ្នាំដោយគ្មានព្យាការីធំៗ។ មានហាបាគុក និង ព្យាការីតូចៗផ្សេងទៀតប៉ុន្តែអេសាយគឺជាព្យាការីធំចុងក្រោយ។ ហើយមនុស្សនៅសម័យ នោះ មិនមាននរណាម្នាក់ហៅគាត់ចេញឡើយ។ ពួកគេរសាត់អណ្តែត។ ប៉ុន្តែ នៅ តែជារាស្ត្ររបស់ព្រះ បានរសាត់អណ្តែតទៅស្រុកនោះ ឥឡូវ—ដែលយើងឃើញពួកគេនៅក្នុងនោះពេលយេរេមាមកថ្លែងទំនាយឲ្យពួកគេ។ ហើយយេរេមា...គាត់ថ្លែងទំនាយមុនការនិរទេសហើយគាត់ក៏និរទេសជាមួយគេដែរ។

25 ហើយបន្ទាប់មកជាការពិត ដានីញ៉ែល មកបន្ទាប់ពីយេរេមា។ ហើយដានីញ៉ែលនិយាយថា គាត់យល់តាមរយៈបទគម្ពីរ កំឡុងពេល៧០ឆ្នាំ ដែលពួកគេនៅ ទីនោះ។

26 ការពិត មានព្យាការីផ្សេងទៀតក្នុងចំណោមពួកគេ ដែលចង់ធ្វើនឹមនេះ ពេលដែលគាត់បានដាក់នៅលើក របស់គាត់ ដែលវាជារឿងតូចមួយ ដែល "ក្នុងរយៈពេលពីរឆ្នាំ ហើយ ព្រះជាម្ចាស់នឹងនាំគេត្រលប់មកវិញ" ប៉ុន្តែ យេរេមា

ដឹងថាខុស ពីរឿងនោះ។ ហើយយើងដឹងពីអ្វីដែលបានកើតឡើងដល់ព្យាការីជាអ្នកដែល ថ្លែង ទំនាយខុសគាត់ស្លាប់នៅក្នុងឆ្នាំនោះ។ ដូច្នេះព្រះជាម្ចាស់នឹងមិនអនុញ្ញាតិឲ្យគាត់ឈរនៅបានទេ។

27 ហើយឥឡូវយើងកត់សម្គាល់ស្ថានភាពនៃមនុស្សនៅក្នុងសម័យនោះ។ ឥឡូវខ្ញុំមិនចង់ឲ្យអ្នកយល់ច្រឡំពីខ្ញុំ (ខ្ញុំ—ខ្ញុំមិនតម្រង់រក) ក្នុងអ្វីដែលខ្ញុំចង់និយាយនៅទីនេះគឺខគម្ពីរខ្លះនិង កំណត់សម្គាល់តូចមួយ។

28 ខ្ញុំមិនធ្លាប់បាន—បានកត់ត្រាខគម្ពីរ និងអ្វីផ្សេងទេ។ ប៉ុន្តែបន្ទាប់ពីខ្ញុំឆ្លងកាត់២៥ឆ្នាំលើកទីពីរហើយ ខ្ញុំ—ខ្ញុំមិនចងចាំដូចពីមុនឡើយដូច្នេះខ្ញុំសរសេរខគម្ពីរ និង អ្វីដែលដឹងពីនោះ កន្លែងដែលខ្ញុំត្រូវទៅតែប៉ុនោះ។ ហើយ មានពេលច្រើនដើម្បី អធិស្ឋានដល់អ្នកជម្ងឺនិងអ្នកផ្សេងទៀតហើយចាកចេញទៅខ្ញុំមិនមានពេលដើម្បី រៀនតាមអ្វីដែលខ្ញុំគួរឡើយ។

29 ឥឡូវ ប៉ុន្តែនេះជាព្យាការីធំនៅសម័យនោះ គឺយេរេមា ហើយគាត់ជាអ្វីមួយនៃលំដាប់អេម៉ុស និង ព្យាការីដទៃទៀតដែលងើបឡើង។ គាត់ត្រូវបានឆេះឆួលឡើងនៅពេលគាត់បានឃើញស្ថានភាពរបស់ប្រជាជាតិ។ ឥឡូវមានទីតាំង...

30 ជួនកាលពេលអ្នកនិយាយពីប្រជាជាតិ វាប្រហែលជាការឆ្លុះបញ្ចាំងពី—ពីក្រុមមួយច្បាស់លាស់។ វាមិនមែនដូច្នោះឡើយ។ វាជារូបភាពទាំងអស់របស់ប្រជាជាតិ។ ហើយយើងឃើញសព្វថ្ងៃនេះ ការ—ការប្រៀបធៀបស្ថានភាពនៅថ្ងៃ នេះដូចជាថ្ងៃរបស់យេរេមា ដែលប្រជាជាតិទាំងអស់បានចូលទៅតិច ឬច្រើនទៅក្នុងការកំផិត ជារបៀបដែលខ្ញុំនិយាយ ជាការឃ្លាតឆ្ងាយពីព្រះ។ ហើយការធ្វើបែបនោះ វាជាការធ្វើឲ្យតុអធិប្បាយចុះខ្សោយ។ ពីព្រោះ បើតុអធិប្បាយអាចឈរត្រង់និងព្រមជាមួយព្រះបន្ទូលរបស់ព្រះ ព្រះជាម្ចាស់នឹង គង់ក្នុងគ្រប់ក្រុមជំនុំដូចទ្រង់កំពុងធ្វើចលនាចំណោមយើងដែរ។ ប៉ុន្តែពួកគេត្រូវបាននាំ ចេញទៅឆ្ងាយពីទីនោះ។ ហើយនោះគឺជាអ្វីដែលខ្ញុំ—ខ្ញុំចង់និយាយនៅព្រឹកនេះ។ សព្វថ្ងៃយើងឃើញថាវាជាការពិតគ្រប់សម័យកាល។

31 ខ្ញុំជឿលើអេម៉ុស ពេលខ្ញុំសំដៅចំពោះ គាត់កាលច្រើនឆ្នាំកន្លង ដែលគាត់និយាយថាគាត់គឺ "មិនមែនជាព្យាការីក៏មិនមែនជាកូនប្រុសរបស់ព្យាការីផង" ប៉ុន្តែគាត់និយាយថា "ពេលតោគ្រហឹម នរណាអាចតាំងនៅបាន ក្រៅពីភ័យខ្លាច?"

32 ហើយ បើសិននរណាម្នាក់ធ្លាប់ឮ តោគ្រហឹមនៅវាលរហោស្ថាន អ្នកប្រហែលជាឮសម្លេងវាដូចជាសម្លេងឆ្នាប៉ុណ្ណោះ។ ប៉ុន្តែធ្លាប់មានតោមួយ គ្រហឹមក្នុងទីស្មសាន គ្រប់យ៉ាងត្រូវតែប្រុងប្រយ័ត្ន។ ខ្ញុំធ្លាប់ដេកក្នុងព្រៃដើម្បីប្រមាញ់ពួក វា។ ហើយ វាជាស្តេចចតុបាតពេលតោនោះគ្រហឹម សូម្បីសត្វល្អិតអណ្តើកមាស ក៏ឈប់យំដែរ គ្រប់យ៉ាងធ្វើដូចគ្នា។ ឆ្កែ—ឆ្កែព្រៃ និង—និងសត្វស្វាន ស្រែកឡើងដែរនិងសត្វផ្សេងទៀតនិងការកញ្ច្រៀវរបស់របស់ស្វា សត្វល្អិតអណ្តើក មាស អ្នកមិនអាចសូម្បីតែឮការគិតរបស់ខ្លួនផង ប៉ុន្តែពីចម្ងាយទុកឲ្យតោ គ្រហឹម ចុះហើយសត្វអណ្តើកមាស ទាំងអស់នឹងឈប់យំ។ ឃើញទេគ្រប់យ៉ាងគឺខ្លាចវា។ តែទោះបីជាមានវត្ថុជាច្រើនអាចសម្លាប់វាក៏ដោយប៉ុន្តែវាត្រូវបានស្គាល់ថា ជាស្តេចក្នុងចំណោមសត្វចតុបាត។

33 គាត់និយាយ "ពេលតោគ្រហឹម នរណាអាចធ្វើអ្វីក្រៅតែពីភ័យខ្លាច?" គាត់និយាយ "ដូច្នេះ បើព្រះជាម្ចាស់មានបន្ទូល គ្មាននរណាអាចធ្វើអ្វីបានទេក្រៅពីការថ្លែងទំនាយ?"

34 ហើយខ្ញុំគិត នោះគឺស្ថានភាពត្រូវបានជួប ដែលជួយចម្រុញដល់សព្វថ្ងៃ។ ព្រះជាម្ចាស់មានបន្ទូល។ ឃើញ?ហើយយើងឃើញដៃបានសរសេរនៅលើជញ្ជាំង វាងាយស្រួលក្នុងការថ្លែងទំនាយ និង ឃើញថាយើងកំពុងនៅសម័យចុងក្រោយ។

35 ហើយយើងកំពុងឃើញព្រះជាម្ចាស់ ពីគ្រប់ចំនុចនៃនិកាយ តាមរបៀបកាតូលិកនិយម ពីក្រុមជំនុំប្រូតេស្តស្តង់ ព្រះពុទ្ធ និង អ្វីទៀត ពីប្រទេសឥណ្ឌា និងអ្វីផ្សេងទៀត។ ទ្រង់កំពុងត្រាស់ហៅរាស្ត្ររបស់ទ្រង់ទាំងអស់ មកជួបជុំគ្នា។ ហើយ ខ្ញុំ—ខ្ញុំរីករាយសម្រាប់ការនោះ នឹងឃើញថ្ងៃនេះមកដល់។ ឥឡូវ យើង...វា—វាជា ថ្ងៃអស្ចារ្យ ជាអភ័យឯកសិទ្ធិពិសេសអស្ចារ្យមួយ។

36 នោះគឺ បើខ្ញុំត្រូវតែ បើខ្ញុំដឹងមុនថាពិភពលោក ពេលដែលយើងមានព្រលឹងចេញពីព្រះជាម្ចាស់ នោះគឺយើង ព្រោះយើងនៅជាមួយទ្រង់តាំងពីមុនគ្រឹះផែនដី។ ព្រោះមានតែទម្រង់តែមួយនៃជីវិតអស់កល្បនោះគឺជាព្រះជាម្ចាស់។ ហើយជាផ្នែកមួយនៃទ្រង់។ យើងមិនមែនជាអ្វី ដែលច្រើនដូចដែលយើងដឹង—និងគិតនោះទេ ប៉ុន្តែយើងនៅក្នុងព្រហរទ័យរបស់ ទ្រង់នូវអ្វីដែលយើងមានមុនគ្រឹះ នៃផែនដី។ ពីព្រោះយើងជាផ្នែកមួយនៃទ្រង់ ដូចជាកូនប្រុសខ្ញុំផ្នែកមួយនៃខ្ញុំ ហើយ ខ្ញុំជាផ្នែក

មួយនៃឪពុករបស់ខ្ញុំ ហើយបន្តទៅទៀត។ យើងជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ ដោយអ្វីដែលទ្រង់ដឹងពីមុនមក។

37 ត្រលប់ទៅវិញ បើសិនជាខ្ញុំអាចដឹងដូចជាខ្ញុំដឹងឥឡូវ និងអាចមើលឃើញរយៈពេលវេលាទាំងមូល ដោយទ្រង់គួរតែបានមានបន្ទូលនឹងខ្ញុំ "តើពេលវេលាមួយណាដែលអ្នកចង់រស់នៅ?" ខ្ញុំនឹងនិយាយ គឺពេលវេលានេះ ជាពេលមុននឹង—បញ្ចប់នៃប្រវត្តិសាស្ត្រពិភពលោក និង ពេលកំពុងដែលនគរព្រះត្រូវបានស្ថាបនាលើផែនដី។ ខ្ញុំគិតថាវាជាពេលវេលាដ៏មានសិរីរុងរឿងជាងសម័យណាៗ ទាំងអស់គឺឥឡូវនេះ។

38 យើងឃើញថានៅទីនេះប្រជាជនអ៊ីស្រាអែល ត្រូវបានចោទប្រកាន់ពី ព្យាការីពេលព្រះជាម្ចាស់រើសតាំងគាត់ និង បញ្ជូនទៅ ពួកគេត្រូវបានចោទប្រកាន់លើបាបធំៗពីរ។ ហើយយើងចង់និយាយពីបាប គឺរឿងធំពីរនោះ ដែលពួកគេបានធ្វើ។ ហើយពីទីនោះយើងចង់ធ្វើការរីកចម្រើនតាមរយៈវា។ ឥឡូវ ពួកគេបានបែរចេញពីព្រះជាម្ចាស់ ជាប្រភពទឹករស់ និងកាប់ឆ្ការកអាងទឹកដោយខ្លួនឯង។ ពួកគេបានប្រែពីអ្វីដែលព្រះជាម្ចាស់ប្រទានដល់គេ និង បានកាប់ឆ្កាអ្វីមួយ ដែលពួក គេបានធ្វើដោយខ្លួនឯង។ ហើយអាងទឹកទាំងនេះ ចូរអ្នកកត់សម្គាល់ថា គាត់បាន ពួកវាបានបែក ហើយធ្លុះធ្លាយបាត់ហើយ។

39 ឥឡូវ អាងទឹកបែកបាក់មិនអាចផ្ទុកទឹកបានឡើយ។ វាបានធ្លុះធ្លាយ។ ខ្ញុំធំឡើងក្នុងស្រែចំការខ្ញុំស្គាល់ពីអាងចាស់ៗជាយ៉ាងណាព្រមទាំងការលំបាកដែលយើងមានជាមួយវា។

40 ហើយរូបភាពនៃអាងធ្លុះធ្លាយនេះជា—ជារូបភាពយ៉ាងល្អមួយខ្ញុំគិតនៅថ្ងៃនេះ ថាពេល(របស់យើង)គ្រប់យ៉ាង ដែលយើងព្យាយាមធ្វើ ដើម្បីប្រមូលមនុស្សមកជុំគ្នា ប្រមូលមនុស្សមកទាំងអស់គ្នាយកក្រុមជំនុំ មកជុំគ្នាវានៅតែជាដែននៃការព្យាយាម បែបចំណេះដឹង។ យើងព្យាយាមធ្វើឲ្យមេតូឌីសក្លាយជាបាបទីស្ទ និងបព្រ្ហាសគ្នាមកវិញដែរ រួមទាំងនិកាយផ្សេងៗទៀត។ នោះគឺមិនមែនជាកម្មវិធីរបស់ព្រះជាម្ចាស់ឡើយ ដែលវាចាប់ផ្តើមបែបនោះ។

41 ព្រះជាម្ចាស់មានកន្លែងប្រជុំគ្នាមួយប៉ុណ្ណោះ។ ទ្រង់មានបន្ទូលពីរឿនោះនៅក្នុងគម្ពីរនិក្ខមនំថា "យើងបានរើសទីកន្លែងដើម្បីដាក់នាមរបស់យើងនិង ជាកន្លែងតែមួយដែលយើងជួបនឹងមនុស្ស។" ហើយ ទ្រង់បានរើសទីតាំងដើម្បី

ដាក់នាមទ្រង់។ ហើយកន្លែងដែលទ្រង់ដាក់នាមទ្រង់នោះជាកន្លែងដែលទ្រង់ជួបសាសន៍ អ៊ីស្រាអ៊ែល។ ហើយ ទ្រង់មានកន្លែងដែលទ្រង់ជួបក្រុមជំនុំទ្រង់នៅសព្វថ្ងៃ និង ទ្រង់រើសឈ្មោះនោះ និង នាមនោះគឺព្រះយេស៊ូវគ្រីស្ទ។ ហើយ នៅទីនោះជាកន្លែងដែលទ្រង់ជួបអ្នកជឿពិតប្រាកដ ពេលដែលគេ នៅក្នុងព្រះយេស៊ូវគ្រីស្ទ។ ដោយនោះជាកន្លែងដែលព្រះជាម្ចាស់រើសដាក់នាមរបស់ទ្រង់។

អ្នកនិយាយ "នាមរបស់ព្រះជាម្ចាស់?"

42 ទ្រង់មានបន្ទូល"ខ្ញុំបានមកដោយព្រះនាមព្រះបិតារបស់ខ្ញុំ"ដូច្នេះ នេះជាកន្លែងដែលព្រះបានដាក់ព្រះនាមទ្រង់ គឺក្នុងព្រះគ្រីស្ទ។ ហើយ នៅក្នុងព្រះគ្រីស្ទគឺជាកន្លែងដែលយើងអាចចូលនៅក្រោមព្រះលោហិតដែលបង្ហូរ និង មានការប្រកបគ្នាយ៉ាងពិតប្រាកដ។

43 ព្រះជាម្ចាស់បានបង្កើតកម្មវិធីរបស់ទ្រង់ តាំងពីដំបូងមកក្នុងសួនអេដែន ជាកន្លែងដែលទ្រង់អាចជួបមនុស្ស ហើយ នោះមិនមែនការយល់ដឹងបែបចំណេះដឹងឡើយ បើវាដូច្នេះ អេវ៉ាពិតជាប្រាកដនៅក្នុងជួរជាមួយកម្មវិធីរបស់ទ្រង់។ ប៉ុន្តែយើងដឹងថាការទទួលយករបស់នាងនូវទស្សនៈចំណេះរបស់សាតាំង "ពិតណាស់ព្រះជាម្ចាស់នឹងមិនធ្វើ" ប៉ុន្តែព្រះជាម្ចាស់មានបន្ទូលថា ទ្រង់នឹងធ្វើ! ហើយដូច្នេះទ្រង់ជ្រើយកទីតាំងនៃការប្រោសលោះ និង វាជាលោហិត ហើយនោះមិនមែនជាទស្សនៈចំណេះប្រាជ្ញាឡើយ។

44 ដូច្នេះ យើងគ្រាន់តែវាយខ្យល់ប៉ុន្តែវាគឺជានិស្ស័យមនុស្សដែល—ដែលមនុស្សនឹងព្យាយាមធ្វើ—ធ្វើបែបនោះ។ បើយើងមានពេល យើងនឹងបំបែកវាជាចំណែកៗ ប៉ុន្តែខ្ញុំមិនត្រូវការលេវនោះឡើយ។ ដូច្នេះយើងព្យាយាមធ្វើឲ្យវាក្លាយជាភាពងាយស្រួលតាមតែអាចធ្វើទៅបាន "អាងទឹកដែលលិច។" ហើយយើងឃើញថាវា—វា ពិតជាកើតឡើងម្តងទៀតវាជារូបភាពនៃសម័យកាលរបស់យើងដែលយើងកំពុង រស់នៅ ពីអស់ទាំងការប្រឹងប្រែងរបស់យើង។

45 ហើយ មិនព្រងើយចំពោះការខិតខំ ដែលជាអ្នកបម្រើរបស់ព្រះជាម្ចាស់ឡើយ ដែលទោះបីជានាមនៃព្រះនាមព្រះយេស៊ូវគ្រីស្ទ។ ទ្រង់គួរត្រូវបានតម្កើង សូម្បីតែព្រះនាមរបស់ទ្រង់ក៏ត្រូវឲ្យនចំពោះ និងការគោរពដែរ។ ហើយបណ្តាញផ្សាយដំណឹងល្អដែលមានទូទាំងផែនដី និង បន្តទៀត នៅសម័យចុងក្រោយនេះខ្ញុំគិតថា

យើងនៅតែមិនអាចធ្វើឲ្យមនុស្សមានចិត្តតែមួយបានទេ រហូតទាល់តែ យើងធ្វើឲ្យពួកគេ នៅក្រោមលោហិតព្រះយេស៊ូវ។ នោះជាកន្លែងតែមួយគត់ ដែលយើងនឹងមានសុវត្ថិភាព។

46 មានអ្នកហៅខ្ញុំ មិនជាយូរឡើយ ពីភាគខាងកើត និង និយាយ "បងប្រុសប្រានហាំខ្ញុំឮថាអ្នកបានផ្លាស់ទៅ—ទៅអារីហ្សូនណា ហើយអ្នកបង្កើត—កន្លែងដែលអ្នកមានសុវត្ថិភាព។" ហើយអ្នកដឹងហើយថាសារបានមកដល់ ព្រះអម្ចាស់មានបន្ទូលប្រាប់ខ្ញុំ នូវអ្វីដែលនឹងកើតឡើងនៅអាឡាស្កា និង បន្តមក កាលីហ្វរនីញ៉ាដែលវានឹងមាន ហើយវាគឺមាននៅថ្ងៃនោះ។ ពួកគេនិយាយថា "ឥឡូវ បើវារញ្ជួយគ្រប់ទីកន្លែង តើកន្លែងណាដែលមានសុវត្ថិភាព?"

47 ខ្ញុំនិយាយ "មានកន្លែង សុវត្ថិភាពដែលខ្ញុំស្គាល់។ នោះគឺក្នុងព្រះគ្រីស្ទ។ សម្រាប់ អស់អ្នក ដែលនៅក្នុងព្រះគ្រីស្ទនឹង..." វាគឺជាកន្លែងតែមួយខ្ញុំស្គាល់។

48 ឥឡូវ យេរេមាក៏ត្រូវបានហៅ ផងដែរថា "ព្យាការីទំនួញ។" ហើយពីព្រោះខ្ញុំជឿ ដែលអាចធ្វើឲ្យព្យាការីយំ—យំ ជាជាង ព្រោះគាត់ជាព្យាការី (ហើយព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដូច្នេះ) និង ឃើញមនុស្សដើរតាមប្រពៃណីរបស់ ពួកគេ និង គិតថាពួកគេមិនអីទេ និង គ្មានផ្លូវទាល់តែសោះដើម្បីបំបែរពួកគេមកវិញ។

49 សម្រាប់ពួកគេនឹងទៅកាន់ការនិរទេសតែម្តង ព្រោះយើងដឹងថាអ្នកច្រូតអ្វីដែលអ្នកសាបព្រួស ដោយមិនគិតពីអ្នកជានរណា អ្នកជាអ្វីទេ។ ហើយយើងជាប្រជាជាតិបានច្រូត...ឬសាបព្រួស ជាជាងទទួលបានការច្រូតកាត់។ ខ្ញុំនិយាយនៅថ្ងៃស្អែក បំណងព្រះទ័យរបស់ព្រះ នៅរសៀល *ការឃើចាប់នៃកំណើត* ហើយខ្ញុំ—និងខ្ញុំបានប៉ះវានៅក្នុងនោះ ដែលយើងមិនអាចទទួលបានដោយភាពទទេឡើយ។ យើងច្រូតកាត់អ្វីដែលយើងសាបព្រួស។

50 ហើយបើព្រះជាម្ចាស់ អនុញ្ញាតឲ្យយើងជាប់នៅ ក្នុងភាពខូចរបស់យើងនៃគ្រីស្ទបរិស័ទសព្វថ្ងៃ និង បានធ្វើឲ្យខូចមនុស្សចូលទៅក្នុងសេចក្តីទាំងនេះដែលហៅថាគ្រីស្ទានដូចបងប្អូនប្រុស ម៉ុរី ធ្លាប់និយាយ "ទ្រង់នឹងធ្វើសំណើរ ដោយក្រមសីលធម៌ក្នុងការប្រោសឡើងវិញនូវក្រុងសូដុំ និង កូម៉ូរ៉ា និង សូមទោសសម្រាប់ការដុតបញ្ឆេះពួកគេ។" នោះគឺត្រឹមត្រូវណាស់ ព្រោះព្រះជាម្ចាស់នៅតែយុត្តិធម៌។ ហើយកន្លែងដែលមានអយុត្តិធម៌វាគឺ—វាគឺក្លាយជាភាពបរិសុទ្ធ នៃ

ទ្រង់ និង ព្រះបន្ទូលទ្រង់ដែលបានធ្វើឲ្យមនុស្សច្រូតកាត់អ្វីដែលពួកគេសាប ព្រោះ ហើយ យើងត្រូវតែធ្វើដូច្នោះ។

51 ឥឡូវ ចំណាំថាពួកគេបានចាកចេញពីទ្រង់ជាប្រភពទឹករស់ និងបានជីកអាង ទឹកមួយសម្រាប់ខ្លួនឯង។

52 ឥឡូវ ប្រហែលមានអ្នកខ្លះនៅទីនេះមិនយល់ពីអ្វីដែលជាអាងទឹក។ អាងទឹក គឺជាអាងដែលមនុស្សធ្វើ ជំនួសកន្លែងរបស់អណ្តូង។ វាជាអ្វីមួយដែលនរណាម្នាក់ ជីក។ ហើយតើប៉ុន្មាននាក់ដែលស្គាល់ថាអាងទឹកយ៉ាងម៉េច? ល្អ។ ត្រូវហើយ មាន មនុស្សនៅតាមជនបទច្រើនគ្នានៅទីនេះ។ ដូច្នេះ ពួកគេ...ខ្ញុំចងចាំពីអាងទឹកចាស់ មួយនៅកន្លែងមួយ វាមានរាងយ៉ាងណា ហើយ ខ្ញុំតែងតែភ័យខ្លាចក្នុងការផឹកទឹក នោះ។ វាជា—អាងធ្វើដោយមនុស្ស។ ហើយ វាតែងតែមិនអាចពឹងបាន។ អ្នកមិន អាចទុកចិត្តដល់អាងអាងទឹកឡើយ។

53 ឥឡូវអ្វីដែលមនុស្សធ្វើតែងតែមិនល្អ។ ប៉ុន្តែវាដូចជា—ព្រះអម្ចាស់ដាក់វាទៅ ក្នុង—ក្នុង—ក្នុងវដ្តរបស់វានិង ផែនដីត្រលប់វិញរាល់ឆ្នាំ រាល់ពេលដែលវាឆ្លងទៅ រាល់ថ្ងៃ រាល់ម៉ោង និងព្រះអាទិត្យលិចចុះ វាមិនដែលខានឡើយ។ ប៉ុន្តែនាឡិកា ដែលល្អបំផុតដែលយើងមាន វាខុសច្រើននាទីក្នុងមួយខែ នោះមិនជាទីសង្ស័យ ឡើយ។ ប៉ុន្តែអ្នកឃើញទេ គ្រប់អ្វីដែលព្រះជាម្ចាស់បានធ្វើគឺល្អឥតខ្ចោះ និង អ្វី ដែលមនុស្សធ្វើគឺមិនបានឥតខ្ចោះឡើយ។ ដូច្នេះ ហេតុអ្វីបានជាទទួលអ្វីដែល មនុស្សធ្វើ ពេលដែលអ្នកមានអ្វីដែលល្អឥតខ្ចោះរួចហើយ?

54 ខ្ញុំតែងតែនិយាយរឿងនោះដែលយើងជាពេនតេកុស។ មើល យើងដឹង ហើយ យើងមិន—យើងមិននៅក្រៅលំដាប់លំដោយនោះឡើយ នៃព្រះជាម្ចាស់ យើងមិន ជឿ ប៉ុន្តែយើងក៏ដឹងដែរថាក្នុងចំណោមយើង យើងមានអ្នកព្យាយាមក្លែងបន្លំតាម មិត្តដ៏ទៃទៀត។ នោះជាមនុស្សតែប៉ុណ្ណោះ។ ពួកគេព្យាយមធ្វើបែបនោះ។ ពួកគេធ្វើ វានៅក្នុងគម្ពីរ "ម្នាក់ 'ខ្ញុំមកពីប៉ូល' 'ខ្ញុំមកពីស៊ីឡាស'" និង តទៀត។ ប៉ុន្តែ ពួកគេ ពួកគេព្យាយាមក្លែងបន្លំអ្វីដែលម្នាក់ទៀតបានធ្វើ ឬ កំពុងធ្វើ។

55 ប៉ុន្តែហេតុអ្វីបានជាអ្នកទទួលការក្លែងបន្លំខុស ខណៈដែលផ្កាយពេញដោយ វត្ថុដែលមិនមែនបន្លំ ពេលដែល "សេចក្តីសន្យាមានសម្រាប់អ្នក និង សម្រាប់ កូនចៅរបស់អ្នក"? ហេតុអ្វីយើងទទួលយកអ្វីដែលខុសគ្នា? ហេតុអ្វីបានជា យើងយកគោលជំនឿសាសនា ឬ លទ្ធិជំនឿ កាលបើព្រះគម្ពីរគឺជា ព្រះបន្ទូល

របស់ព្រះដែលគ្មានលាយ? ហេតុអ្វីបានជាយើងព្យាយាមបន្ថែមឬដក កាលបើព្រះអម្ចាស់យេស៊ូវមានបន្ទូល វិវរណៈ ២២:១៨ "អស់អ្នកណា ដែលយកអ្វីចេញឬបន្ថែមអ្វីនៅក្នុងសេចក្តីទាំងនេះ នោះចំណែករបស់គេនឹងត្រូវបានដកចេញពីបញ្ជីរជីវិត"?

56 ជាដំបូង ពេលដែលព្រះជាម្ចាស់បានដាក់មនុស្សជាតិនៅលើផែនដី ទ្រង់មានបន្ទូលប្រាប់គេឲ្យរស់នៅ ដោយព្រះបន្ទូលទ្រង់។ ឥឡូវព្រះបន្ទូលរបស់ព្រះប្រៀបដូចជាច្រវាក់ អ្នកឆ្លងកាត់ស្ថាននរកដោយព្រះបន្ទូលនោះ ហើយ ច្រវាក់របស់វាគឺមានភាពល្អបំផុតនៅការតភ្ជាប់ដែលខ្សោយបំផុត ហើយ ព្រះជាម្ចាស់មានព្រះទ័យ ចង់ឲ្យយើងរក្សាគ្រប់ទាំងពាក្យនៃព្រះបន្ទូល។ ឥឡូវ នោះជារឿងទីមួយនៃព្រះគម្ពីរ គឺខុសត្រឹមតែមួយបន្ទូល បានពន្លិចមនុស្សជាតិឲ្យធ្លាក់ទៅក្នុងភាពងងឹត នៃសេចក្តីស្លាប់។

57 ព្រះយេស៊ូវបានយាងចំកណ្តាលព្រះគម្ពីរ ហើយ ទ្រង់មានបន្ទូលថា "មនុស្សមិនរស់ ដោយសារតែនំប៉័ងប៉ុណ្ណោះឡើយ។ ប៉ុន្តែពីគ្រប់ពីព្រះបន្ទូលរបស់ព្រះផង។" មិនមែនត្រឹមជាផ្នែកខ្លះនៃព្រះបន្ទូលឡើយ ឬ កៅសិបប្រាំបួនក្នុងចំណោមមួយរយឡើយ ប៉ុន្តែពីគ្រប់ទាំងព្រះបន្ទូល ដូចជាអ័រដាំ និង អេវ៉ាដែរ។

58 ហើយនៅចុងក្រោយនៃព្រះគម្ពីរវិវរណៈ:២២:១៨ ទ្រង់មានបន្ទូលថា "អស់អ្នកណានឹងដកព្រះបន្ទូលចេញ ឬបន្ថែមពាក្យណាមួយទៅក្នុងនោះ!"

59 ដូច្នេះ ហេតុអ្វីបានជាយើង ចាំបាច់ត្រូវដាក់បញ្ចូលក្នុងនេះ នូវអ្វីដែលជាគំនិតរបស់នរណាម្នាក់ពីអ្វីមួយ កាលបើនេះជាគំនិតនៃព្រះបន្ទូលផ្ទាល់អំពីវា? យើងចង់យកអ្វីដែលទ្រង់មានបន្ទូល។ ហើយវាក៏បានសរសេរដែរ "ចូរឲ្យពាក្យរបស់មនុស្សក្លាយជាកុហក ហើយបន្ទូលរបស់យើងក្លាយជាសេចក្តីពិត។"

60 នោះហើយជាអ្វីដែលជាបញ្ហាលើព្យាការីនេះ។ ក្នុងសម័យកាលយេរេមា គាត់ជាព្យាការី គាត់មានព្រះបន្ទូលរបស់ព្រះអម្ចាស់។ និង មិត្តម្នាក់នេះ ព្យាយាមដាក់បញ្ចូលអ្វីមួយទៅក្នុងនោះ ដូច្នេះវាមិនអាចពឹងផ្អែកបានឡើយ។ ហើយខ្ញុំព្យាយាមប្រដូចអាងទឹកនេះ ឥឡូវ ជាប្រព័ន្ធទាំងនេះដែលព្យាយាមយក និងយកទីតាំងដើមនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។

61 ត្បិតគ្មានអ្វីអាចជំនួសកន្លែងវាបានឡើយ។ នោះជាព្រះជាម្ចាស់។ "កាលពីដំបូងឡើយមានព្រះបន្ទូល ហើយ ព្រះបន្ទូលគង់ជាមួយព្រះជាម្ចាស់ ហើយ ព្រះបន្ទូលគឺជាព្រះ។ ហើយព្រះបន្ទូលបានក្លាយ ជាសាច់ឈាមរស់ក្នុងចំណោមយើង។" ហើយហេព្រើរ ១៣:១៨ និយាយថា"ទ្រង់នៅតែដដែលគឺពីថ្ងៃម្សិលមិញ ថ្ងៃនេះ ហើយទៅដល់អស់កល្បជានិច្ចតទៅ" តើយើងអាចដកចេញពីនោះដោយរបៀបណា? វាត្រូវតែជាសេចក្តីពិត។ ទ្រង់នៅតែដដែល។ ទ្រង់នៅតែដដែលគ្រប់ទាំងគោលការណ៍។

62 នោះជាហេតុផលដែលអ្នករីករាយជាមួយវា អ្នកជាបាបទីស្ត មេតូឌីស្ត និង កាតូលិក និង ព្រីសប៊ីធីរៀន និង ជាអ្វីផ្សេងទៀត រីករាយជាមួយវត្តមាននោះ។ ចំនុចណាមួយនៅក្នុងអ្នកថា អ្នកទទួលព្រះជាម្ចាស់។ ជួនកាលអាចជារបៀបចំណេះប្រាជ្ញា ឬអាចជាអ្នកមានអារម្មណ៍ ដឹងពីអំណាចចេស្តាព្រះជាម្ចាស់ និង អ្នកជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ប៉ុន្តែពេលអ្នកអាចមករកព្រះពិតប្រាកដ និង ស្គាល់ពីទីតាំងរបស់អ្នកក្នុងទ្រង់ ជាបុត្រាបុត្រីរបស់ព្រះ នោះជាអ្វីដែលនាំឲ្យអ្នកមានភាពរំភើបចិត្ត ដែលព្រះទ្រង់មានបំណងចង់ឲ្យអ្នកមាន។

63 ឥឡូវយើងកត់សម្គាល់ពីសាវកម៉ាកុស ជំពូក១៦ ព្រះយេស៊ូវមិនមានបន្ទូលថា "ចេញទៅទូទាំងផែនដី និង—និង—និងបង្រៀន" ទ្រង់មានបន្ទូល "ចេញទៅផ្សាយដំណឹងល្អ។" ផ្សាយដំណឹងល្អ គឺ បង្ហាញបញ្ជាក់ពីអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ! "ចេញទៅទូទាំងផែនដី និងបង្ហាញបញ្ជាក់ពីអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធ។"

64 និយាយពីបងប្អូនប្រុសជាម្នាក់ក្នុងចំនោមអ្នកឧបត្ថម នៅ…ការជួបជុំរបស់ខ្ញុំនៅ អិនឌៀអាយណា ក្នុង ប៊ុមបាយ បន្តទៅអាហ្វ្រិកខាងត្បូង និង កន្លែងផ្សេងៗ ជាកន្លែងដែលបេសកជនបានបង្រៀនវាថាជាពាក្យ ឬ ជាទស្សនៈចំណេះដឹង។ ប៉ុន្តែនៅថ្ងៃមួយក្នុងការជួបជុំ ជាកន្លែងដែលព្រះវិញ្ញាណយាងចុះមក ទ្រង់ផ្ទាល់និងបានសង្គ្រោះមនុស្ស៣ម៉ឺននាក់ដែលជាអ្នក ដណ្តប់ដោយសារជាតិជាអ្នកស្រុកដើម នៅលើការហៅតែម្តងនៅលើអាសនា និង នៅកន្លែងដែលពួកគេកំពុងតែឈរ។ ស្ត្រីឈរនៅទីនោះ ដែលអាក្រាតស្ទើរទាំងអស់ តាមរបៀបដូចគាត់មកលើផែនដីនេះ និង គ្រប់ ទាំងនាទីដែលពួកគេលើកដៃទទួលព្រះគ្រីស្ទ…

65 ហើយព្រះវិញ្ញាណបានធ្លាក់មកនៅកន្លែងនោះ និង ប្រោសមនុស្ស២៥០០០ នាក់ឲ្យជាក្នុងពេលតែមួយ ក្រោកចេញពីកៅអីកង់ ជើងម៉ា និង កៅអីលា។ ចៅហ្វាយក្រុងស្នើរខ្ញុំមក ថ្ងៃបន្ទាប់ សូមមើលឥវ៉ាន់ដែលផ្ទុកលើឡាននេះតាមផ្លូវ។

66 ពួកគេមានស្រីៗឈរនៅទីនោះ អាក្រាតដោយមិនដឹងថាពួកគេនៅអាក្រាត។ ប៉ុន្តែពេលព្រះវិញ្ញាណវាយប៉ះពួកគេ ពួកគេឱបដៃដើរចេញពីប្រុសៗរបស់ពួកគេ។

67 ហើយ ខ្ញុំឆ្ងល់ថាយ៉ាងម៉េចកើតដែលយើងនៅអាមេរិកហៅខ្លួនឯងថាជាប្រជាជាតិគ្រីស្ទាន និង នៅក្នុងវត្តមានរបស់ព្រះជាម្ចាស់ រៀងរាល់ឆ្នាំយើងឃើញស្រីៗ ដោះខោអាវចេញកាន់តែច្រើន។ ហើយ អ្នកគួរតែពាក់បន្ថែមមកវិញ។ ហើយ អ្នកពាក់ដណ្តប់ព្រះគ្រីស្ទកាន់តែច្រើន មនសិកាអ្នកដឹងស្ថានភាពរបស់អ្នកក៏កាន់តែច្រើនដែរ។ ជួនកាលខ្ញុំឃើញរបៀបមនុស្សបញ្ចេញកិរិយា នៅតាមផ្លូវ ខ្ញុំឆ្ងល់ថា វាជាបញ្ហាផ្លូវចិត្តឬ។ វាហាក់បីដូចជាពួកគេមិនដឹងពីអ្វីដែលខ្លួនកំពុងធ្វើ អ្វីដែលពួកគេកំពុងធ្វើពួកគេបានធ្វើខ្លួនឲ្យក្លាយជានុយរបស់អារក្ខហើយ ក៏បញ្ជូន ព្រលឹងទៅស្ថាននរកផង។ នោះគឺត្រឹមត្រូវណាស់។ ប៉ុន្តែលោកកិយ៍ស្ថិតនៅក្នុងភាពពុកផុយបែបនោះ នៅសម័យរបស់លោកយេរេមា។

68 ឥឡូវត្រលប់ទៅរឿងអាងទឹកវិញ។ ឥឡូវអាងទឹកនេះ មិនអាចពឹងផ្អែកបានឡើយ ព្រោះវាមិនអាចបំពេញខ្លួនឯងបាន។ ហើយវាត្រូវអាស្រ័យលើភ្លៀងក្នុងតំបន់ដើម្បីបំពេញវាភ្លៀងប្រចាំតំបន់ ឬការចាក់ព្រះចេស្តាជាថ្មីក្នុងតំបន់ ដើម្បីមានការចាក់ចេស្តាបន្តិចនៅ*ទីនេះ* និងបន្តិចនៅ*ទីនោះ*ឬបន្តផ្សេងទៀតដើម្បីបំពេញវា។ដូច្នេះវាមិនអាចពឹងផ្អែកបានឡើយ។ វាមិនអាចបំពេញ ទឹកដោយខ្លួនឯង។ វាមិនមានភាពគ្រប់គ្រាន់ ចំពោះខ្លួនវា។ វាមិនអាចធ្វើបាន។ វាអាស្រ័យតែនឹងភ្លៀងដើម្បីបំពេញវា។

69 បន្ទាប់មកចូរកត់ចំណាពីកន្លែងដែលវា—វាទទួលភ្លៀងរបស់វា កន្លែងដែលវាទទួល បានទឹករបស់វានៅក្នុងអាង។ វាចេញមកពីកំពូលកន្លែងជង្រុកស្រូវ រោងជាកន្លែងដែលភាពគគ្រិចដែលប៉ើងមក វាត្រូវបានលាងសម្អាតដោយភ្លៀង ហើយហូរចូលទៅកាន់អាង ជាអាងធ្វើដោយ–មនុស្ស។ វាស្ទើរតែក្លាយជាអណ្តូងទឹកស្អុយទៅហើយ។ ហើយវាបានមកពីការលោងកំពូល កន្លែងបោកស្រូវ ដែលជាកន្លែងសត្វ មានក្លិនអាក្រក់នៅកន្លែងជង្រុកស្រូវ និងអ្វីទៀត ទុកនៅទីនោះ។

ហើយខ្យល់បក់មកលើ—កម្ទេច និង ឥវ៉ាន់នៅជម្រុក រួចភ្លៀងតំបន់ចូលមកជាមួយ លាងវា ភ្លៀង លាងចេញ។

70 ហើយបន្ទាប់មកទៀតទឹកត្រូវបានផ្ទុកនៅស្នូកដែលមនុស្សធ្វើ ហូរតាមបំពង់ដែលមនុស្សធ្វើ រួចចូលទៅក្នុងអាងមនុស្សធ្វើ។ ហើយពេលវាទៅដល់ទីនោះ វាមិនស្អាតឡើយវាប្រឡាក់ដែលអ្នកត្រូវតែដាក់ កន្ទបតម្រងលើវា បើមិនដូច្នោះ អ្នកមិនអាចផឹកបានឡើយ។ ឥឡូវមើលវាបានលាងចេញពីដំបូល ដោយស្នូកមនុស្សធ្វើ កាត់តាមបំពង់មនុស្សធ្វើ រួចចូលអាងមនុស្សធ្វើ។ និង បន្ទាប់មកមានតម្រងមនុស្សធ្វើនៅពីលើវា ដើម្បីឲ្យបានមើលឃើញសត្វល្អិត និង អ្វីៗទៀតនៅទីនោះ។

71 ឥឡូវ ឥឡូវយើងកត់សម្គាល់ថា នៅក្នុងពីរបីថ្ងៃនេះបន្ទាប់ពីទឹកបានទុកនៅទីនោះ នៅក្នុងការគ្រប់គ្រងរបស់មនុស្សជាអ្នកធ្វើ ឬជាអាង។ សូមអភ័យទោស។ សូមអភ័យទោស។ ត្រូវហើយ។ បន្ទាប់មកវា—បន្ទាប់មកវាបានលាងចេញ គ្រប់អស់ទាំងទេវវិទ្យានិងអ្វី ដែលលាងធ្លាក់ចូលទៅក្នុងនោះ ឥឡូវយើងចូលមករកពេលវាបានទុកនៅទីនោះពីរបីថ្ងៃ វាក្លាយជាទឹកស្អុយ។

72 ហើយមាននរណាដឹងពី ប្រវត្តិសាស្ត្រក្រុមជំនុំ ពេលព្រះជាម្ចាស់បញ្ជូនអ្វីចេញជាសារនិងវាក្លាយជា ស្រស់ថ្មីមកពីព្រះជាម្ចាស់ ហើយបន្ទាប់មក—ជីវិត របស់អ្នកដែលរកឃើញនោះ(ឬអ្វីក៏ដោយដែលអាចអ្នកហៅថាជាអ្នកបំផ្លាស់បំប្រែ ឬតាមអ្វីដែលអ្នកចង់និយាយពីរឿងនោះ) បន្ទាប់ពីមរណៈភាពរបស់គាត់ ដូច្នេះ ពួកគេក៏មានប្រព័ន្ធមួយកើតឡើង ហើយ ពួកគេបង្កើតជាអង្គការ។ ហើយពេលគេបង្កើតជាអង្គការមួយភ្លាម ចេញពីនោះ វាក៏ស្លាប់នៅត្រង់នោះតែម្តង។ វាមិនដែលរស់ឡើងវិញឡើយ។ វាបានធ្វើដូច្នេះគ្រប់សម័យត្រលប់វិញ ស្ទង់មើលទៅក្រោយ។

73 ក្នុងការផ្តល់ការយកចិត្តទុកដាក់ ដល់សង្ឃកាតូលិកនេះ ដែលកំពុងអង្គុយពេលព្រះជាម្ចាស់រៀបចំក្រុមជំនុំ...ឬ មិនបានរៀបចំវាទេ ព្រះជាម្ចាស់មិនដែលរៀបចំក្រុមជំនុំឡើយ។ ទ្រង់មិនធ្វើកិច្ចការនោះឡើយ។ ព្រះគង់នៅជាមួយនឹងកំណើត ថ្មីវិញ មិនមែនការរៀបចំឡើយ ដូច្នេះព្រះជាម្ចាស់ចាប់ផ្តើមក្រុមជំនុំនៅថ្ងៃបុណ្យ ទី៥០។ ហើយ បន្ទាប់មកបន្តទៅ នីសៀ រ៉ូម ពួកគេរៀបចំវា ហើយនោះជាកន្លែងដែលវាបានបាត់អំណាចរបស់វា។

74 បន្ទាប់មកយើងបន្តទៅអ្នកបំផ្លាស់បំប្រែលូធើរៀន និង វាជារឿងអស្ចារ្យ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានប្រទានមក "មនុស្សសុចរិតនឹងរស់ដោយជំនឿ។"

ហើយពេលពួកគេបានផ្ញើ ជំនួសឲ្យគ្រាន់តែយក ទាំងអស់គ្នា ពួកគេទាំងអស់ដើរតាម ពួកគេក៏បង្កើតក្រុមជំនុំលូធីរៀន បំបែកខ្លួនពីក្រុមនេះ ហើយ វាក៏ស្លាប់។

75 បន្ទាប់មកព្រះជាម្ចាស់ក៏លើកចនវេស្លេ ជាមួយការបន្សុតជាសុចរិត ជាសារនៃកិច្ចការទីពីរនៃព្រះគុណ និង វាជារឿងមួយយ៉ាងអស្ចារ្យ។ ប៉ុន្តែបន្ទាប់ពីវេស្លេ និង អាស្បឺរី ពួកគេរៀបចំវា វាក៏ស្លាប់ទៀត។

76 បន្ទាប់មក ក៏ពួកពេទីកុស្តបានចូលមក នឹងការស្តារឡើងវិញនៃអំណោយទាន។ ពួកគេមិនមានបញ្ហាអ្វីទេ មានអ្វីកើតឡើង? រៀបចំវាទៀត ហើយវាស្លាប់ទៀត។ គឺត្រូវតែដូច្នេះ។

77 ឥឡូវក្នុងកណ្តាលនៃរឿងទាំងអស់នោះ ព្រះនៅតែត្រាស់ហៅអ្នកសេសសល់ចេញពីគ្រប់អស់ទាំងសម័យទាំងនោះ។ ទ្រង់ពិតជាធ្វើ។ ហើយសម័យរបស់យើងក៏ចេញមក ជាការប្រមូលមកជុំគ្នា។ ហើយនោះជាអ្វីដែលខ្ញុំគិត ក្រុមអ្នកធ្វើកិច្ចការដំណឹងល្អពេញលេញបានសម្តែងតួនាទី ជាផ្នែកយ៉ាងធំក្នុងការបំបែកជញ្ជាំងនិងនិយាយថា "មិនមានភាពខុសគ្នាក្នុងចំណោមយើងឡើយ។ ចូរឲ្យយើងមកជុំគ្នានិងថ្វាយបង្គំព្រះជាម្ចាស់ក្រោមគោលការណ៍តែមួយមិនមែនក្រោមអង្គការ ឡើយ។" បើវាជាអង្គការខ្ញុំនឹងចុះចេញពីវេទិកានេះឥឡូវ។ ខ្ញុំគ្មានអ្វីធ្វើជាមួយវាឡើយ។

78 វាជាអ្វី វាជាការប្រកបគ្នា និង មិនមែនជាការប្រកបគ្នានៃសាសនាឡើយ។ ប៉ុន្តែប្រកបគ្នាក្នុងព្រះគ្រីស្ទ ដោយចេស្តានៃការរស់ឡើងវិញរបស់ទ្រង់ ដែលជាអ្វីនាំឲ្យមានជីវិត។ វានាំមកនូវកំណើតថ្មី។

79 ហើយ មុនកំណើតបានមកដល់ យើងដឹងថាត្រូវតែមានសេចក្តីស្លាប់មុនកំណើត។ ហើយកំណើតគឺជាភាពរញ៉េរញ៉ៃខ្ញុំមិនខ្វល់ថាជាប្រភេទកំណើតបែបណាទេ។ ទោះថាបើវាជាទ្រុងជ្រូក ឬ—ឬអ្វីក៏ដោយ វាជាភាពរញ៉េរញ៉ៃ។ ដូច្នេះវាជាកំណើតថ្មីវានឹងធ្វើឲ្យអ្នកធ្វើអ្វីដែលអ្នកជាធម្មតាដែលអ្នកមិនគិតថាអ្នកអាចធ្វើបាន។ ប៉ុន្តែពេលអ្នកត្រៀមរួចរាល់ថា នឹងស្លាប់ខ្លួនអ្នក ដូច្នេះអ្នកកើតជាថ្មីជាកំណើត ក្នុងព្រះយ៉ូវគ្រីស្ទបន្ទាប់មកអ្វីមួយ បើជីវិតរបស់អ្នកក្លាយជារូបភាពថ្មីសម្រាប់អ្នក ព្រោះ អ្នកបានទទួលយកមនុស្សនៃព្រះគ្រីស្ទនិងមិនមែនជាទ្រឹស្តីឬសាសនាណាឡើយ។

80 ឬ ទោះបើតាមព្រះបន្ទូលដែលបានកត់ទុក វាត្រូវតែសកម្មដោយព្រះវិញ្ញាណបរិសុទ្ធ។ មិនថាទ្រឹស្តីប៉ុណ្ណា អ្នកដឹងឡើយ វាត្រូវតែទុកឲ្យងាប់ទៅ។ ខ្ញុំអាចមានស្រូវសាឡីមួយក្តាប់បាន ទាល់តែវាបានចូលទៅដំណើរការកន្លែងដែលវាសកម្ម ស្រូវសាឡីមិនរស់ឡើយ។ ហើយអ្នកអាចមានកម្រិតសិក្សាថ្នាក់ដុកទ័រ ភីអេចឌី អិលអិលអ្វីដែលអ្នកចង់បានប៉ុន្តែទាល់តែព្រះវិញ្ញាណមកលើនោះនិងធ្វើឲ្យវាក្លាយជាសកម្មក្នុងអ្នកជាបទពិសោធន៍ផ្ទាល់ខ្លួនជាមួយព្រះជាម្ចាស់បើមិនដូច្នោះ ស្រូវសាឡីនឹងមិនបានផលិតអ្វីល្អឡើយ។ អ្នករៀនវាក្នុងភាពឥតប្រយោជន៍ប៉ុណ្ណោះ។

81 ដូចបុរសជនជាតិអង់គ្លេសម្នាក់និយាយនៅយប់មួយនៅទីនោះ ខ្ញុំពិតជារន្ធត់ពីការនោះណាស់។ គ្រប់អ្វីគាត់បានរៀន ដូចប៉ូល គាត់បានបំភ្លេចទាំងអស់អ្វីដែលគាត់ដឹង ដើម្បីរកឲ្យបានព្រះគ្រីស្ទ ធ្វើអ្វីដែលគាត់គិតថាគាត់មិនអាចធ្វើបាន។

82 ប៉ុន្តែនោះជារបៀប ដែលព្រះជាម្ចាស់បានធ្វើ ទ្រង់បន្ទាបយើងចុះក្នុងប្រព័ន្ធអប់រំរបស់យើង។ មិនមែនខ្ញុំគាំទ្រការមិនចេះអ្វីនោះទេ ប៉ុន្តែខ្ញុំចង់ប្រាប់អ្នកពីភាពខុសគ្នា។ ការសិក្សាអប់រំមិនអាចនាំជីវិតមកឡើយ។វាត្រូវតែជាកិច្ចការព្រះវិញ្ញាណរបស់ទើបនាំជីវិតមកហើយជីវិតនោះមិនមែនគ្រាន់តែមកជាការផុសផុល តាមរយៈចំណេះដឹងឡើយ។ វាត្រូវតែចេញមកពីព្រះគម្ពីរ ការផុសផុលនៃព្រះបន្ទូល ហើយព្រះបន្ទូលនោះនៅដូចកាលពីម្សិលមិញថ្ងៃនេះនិងរៀងរហូតទៅ។ ហើយបើវា ធ្លាក់មកថ្ងៃនេះនិងក្លាយជាសកម្ម អ្នកនឹងទទួលបានលទ្ធផលដូចគ្នានៅក្នុង កិច្ចការជំពូក២។ ជាការពិត។ វាតែងតែមាននិងតែងតែក្លាយជាបែបនោះព្រោះវាជា ព្រះវិញ្ញាណ ព្រះដែលជាលក្ខខ័ណ នៃបរិយាកាស។

83 វាត្រូវតែមានបរិកាសដើម្បីធ្វើអ្វីៗ។ នោះហើយជាហេតុផល ដែលអ្នកជាមនុស្សត្រូវបានបង្រៀន "នាំកូនរបស់អ្នកមកទីនេះ" ល្អ នោះជាការពិត។ ខ្ញុំរីករាយដែលឃើញកូនស្រីរបស់ខ្ញុំរ៉េបេកាមកក្នុងនេះនិងអង្គុយចុះកាលពីប៉ុន្មាននាទីកន្លងទៅ។ អ្នកខ្លះក្នុងចំណោមអ្នកឃើញខ្ញុំគ្រវីដៃដាក់ស្ត្រីម្នាក់ គាត់ជាកូនស្រីខ្ញុំ ដូច្នេះនាងចូលមកនិងអង្គុយ។ ខ្ញុំចង់ឲ្យនាងទទួលការជ្រមុជដោយវិញ្ញាណហើយហេតុនេះបានជានាងមកក្នុងការប្រជុំ។ នោះជាអ្វីដែលជាបំណងរបស់វា។ វាត្រូវការបរិយាកាស។

84 ដូចជាគ្រូពេទ្យចាស់ប៉ូសស្វសធ្លាប់និយាយ "អ្នកអាចយកពងមាន់ទៅដាក់ក្រោមកូន ឆ្កែវានឹងបើកសំបកមកជាកូនមាន់ហើយ" ហេតុអ្វី?ព្រោះវាជាពងមាន់ ហើយយក ទៅដាក់កន្លែងបរិយាកាសសមស្រប។

85 ខ្ញុំមិនខ្វល់ថាអ្នកជាមេតូឌីស្ត បាបទីស្ត ព្រីសប៊ីធីរៀន អ្វីឡើយ នៅក្នុងបរិយាកាសសមស្រប វានឹងបកសំបកចេញហើយកើតកូនមួយថ្មីរបស់ព្រះជាម្ចាស់។ វាជាបរិយាកាស ដែលធ្វើវាឡើង មិនមានបញ្ហាថានិកាយមួយណា ដែលអ្នកភ្ជាប់ទៅទេ។

86 ធ្លាប់ឃ្វាលហ្វូងគោ។ ខ្ញុំសម្គាល់ឃើញអ្នកត្រួតភូមិភាគពេលយើងនាំពួកគេទៅក្នុងព្រៃ ចេញ—ចេញពីកន្លែងឲ្យចំណី ទៅវាលចិញ្ចឹមសត្វ និង ដាក់ពួកគេនៅក្នុងព្រៃ។ គាត់ឈរនៅនៅទីនោះ និង មើលពួកវាឆ្លងកាត់ក្លោងទ្វា នៅឯពំនូករបង។ គាត់មិនយកចិត្តទុកដាក់លើស្លាកយីហោឡើយ ព្រោះមានឈ្មោះយីហោជាច្រើនឆ្លងកាត់។ ប៉ុន្តែមានរឿងមួយដែលគាត់យកចិត្តទុកដាក់ គឺស្លាកឈាម។ វាត្រូវតែជាពូជសុទ្ធ ហៀហ្វ៊ដ បើមិនដូច្នេះវាមិនអាចឲ្យចូលទៅក្នុងព្រៃបានឡើយ ព្រោះវាជាសមាគមន៍ហៀហ្វ៊ដ ដែលឲ្យស៊ីស្មៅនៅទីនោះ។ វាត្រូវតែមានស្លាកឈាម ដើម្បីរក្សាពូជត្រឹមត្រូវ។

87 ហើយខ្ញុំគិតថានោះជារបៀបដែលនឹងធ្វើនៅថ្ងៃជំនុំជម្រះ។ ទ្រង់នឹងមិនសួរខ្ញុំថាតើខ្ញុំជាមេតូឌីស្ត បាបទីស្ត ពេនតេកុស ឬ ព្រីសប៊ីធីរៀនឡើយ ប៉ុន្តែទ្រង់នឹងពិនិត្យមើលស្លាកឈាម។ "ពេលណាយើងឃើញឈាម យើងនឹងរំលងអ្នកទៅ" នោះជាអ្វីដែលធ្វើ។

88 ដូច្នេះ យើងឃើញថា អាងទឹកនេះ បន្ទាប់ពីពួកវានៅមួយរយៈ ពួកវា...ពួកវាក្លាយជាស្អុយ និង មិនមែនជារបស់ល្អឡើយ។ ហើយ វាក្លាយជា បន្ទាប់មកក៏ក្លាយជាផ្ទះរបស់កង្កែប និង ជីងចក់ និង ពស់ និង សត្វស្លាបល្អិតៗ និង មេរោគ និង អ្វីផ្សេងទៀត ព្រោះវាស្ថិតនៅលក្ខខ័ណជាប់នឹងស្ទៀមដែលទាញទៅក្នុងស្ថានភាពនោះ។ តើអ្នកអាចស្រមៃទេ លាងចេញពីដំបូលជង្រុកស្រូវ ឬ ចេញពីដំបូលផ្ទះនៅក្បែរនោះ និង កន្លែងណាដែលរបស់កកខ្វក់ តើប្រភេទនៃសត្វស្លាបល្អិត និង មេរោគអ្វីខ្លះ និង គ្រប់យ៉ាង ដែលលាងធ្លាក់ចូលក្នុងអាង?

89 ឥឡូវ វាជាឧទាហរណ៍នៃប្រភេទអាង-ធ្វើដោយមនុស្ស។ គាត់បរាជ័យហើយដែលចាប់ផ្ដើមដោយដូច្នេះ។ នេះជាហេតុផល ដែលគាត់ត្រូវការអង្គសង្គ្រោះ។

គាត់មិនអាចសង្គ្រោះខ្លួនឯងឡើយ គាត់មិនអាចធ្វើអ្វីសោះ សម្រាប់រឿងនោះ។ គាត់បរាជ័យ ដោយចាប់ផ្តើមជាមួយវា។ គាត់កើតមកលើផែនដី មានបាប គាត់មកផែនដី និយាយកុហក។ គាត់ជាមនុស្សកុហក ដើម្បីចាប់ផ្តើមដំបូង ដូច្នេះតើលោកកិយ៍អាចធ្វើអ្វីបានសម្រាប់ខ្លួនឯង? តើអាចជាមនុស្សបរិសុទ្ធបែបណា?

90 គ្មានមនុស្សណាបរិសុទ្ធឡើយ។ គ្មានក្រុមជំនុំណាបរិសុទ្ធឡើយ។ វាជាព្រះវិញ្ញាណបរិសុទ្ធ! មិនមែនក្រុមជំនុំបរិសុទ្ធ ពួកមនុស្សបរិសុទ្ធ និង វាជាព្រះវិញ្ញាណបរិសុទ្ធចំណោមមនុស្ស នោះគឺបែបនោះហើយ។ អាមែន។ មិនមែនជាភ្នំបរិសុទ្ធ ដែលពេត្រុសបានឈរ ភ្នំមិនបរិសុទ្ធឡើយ។ ប៉ុន្តែជាព្រះបរិសុទ្ធ ដែលនៅលើភ្នំ ដែលធ្វើឲ្យវាទៅជាបរិសុទ្ធ។ មិនមែនមនុស្សបរិសុទ្ធឡើយ ប៉ុន្តែជាមនុស្សនៃព្រះវិញ្ញាណបរិសុទ្ធ ប្រើនៅក្នុងមនុស្សនោះ ដែលធ្វើឲ្យវាបានបរិសុទ្ធ។ មិនមែនជាមនុស្សឡើយ ប៉ុន្តែជាមនុស្សនៃព្រះវិញ្ញាណបរិសុទ្ធ! វាមិនមែនជាមនុស្សឡើយ ព្រោះគាត់គ្រាន់តែជាមនុស្ស "កើតក្នុងបាប មានរូបរាងជាមានកំហុស ចូលមកផែនដីនិយាយកុហក។"

91 ប្រព័ន្ធធ្វើដោយ-មនុស្សនឹងរក្សាមនុស្សនៅទីនោះ គាត់នឹងបាំងអ្វីៗពីភ្នែកអ្នកមានចំណេះ ភ្នែកពួកអ្នកមានចំណេះប្រាជ្ញា ដែលពួកគេគិតថា "ខ្ញុំជាសមាជិកក្រុមជំនុំ ឈ្មោះខ្ញុំនៅក្នុងសៀវភៅ។ ខ្ញុំបានធ្វើ*នេះ* ។ ឪពុកខ្ញុំជាអ្នក*នេះ* និង អ្វីទៀត។" ស្តាប់ទៅដូចជាត្រឹមត្រូវ ដែលគ្មានអ្វីដែលនិយាយទាស់នឹងវាឡើយ។ ប៉ុន្តែសម្លាញ់អើយ ព្រះយេស៊ូវមានបន្ទូលថា "លើកតែអ្នកដែលកើតជាថ្មីប៉ុណ្ណោះ បើមិនដូច្នេះមិនអាចឃើញបានឡើយ" *ឃើញ*មាន មិនមែនមានន័យថាគាត់មើលឃើញនឹងភ្នែកឡើយ ប៉ុន្តែ*យល់* "*យល់ពី*នគរស្ថានសួគ៌។" ទាល់តែអ្នកកើតក្នុងនោះ!

92 តើខាងបាបទីស្តផ្សាយដំណឹងល្អរបៀបណា តើបុរសនោះឈរទីនោះ និង រិះគន់ហើយនិយាយកំប្លែងពីរឿងនោះយ៉ាងណា? ឃើញ គ្មានអ្វីនៅក្នុង គាត់ដែលអាចទទួលវាបានឡើយ ប៉ុន្តែព្រះជាម្ចាស់ត្រូវតែធ្វើវា ឃើញ។ ព្រះជាម្ចាស់ប្រទានឲ្យគាត់នូវព្រះវិញ្ញាណបរិសុទ្ធ។ ទ្រង់បើកសម្តែងឲ្យឃើញថា នេះមិនមែនជា ការលាក់ពុតឡើយ នេះជាព្រះបន្ទូល។ គាត់ធ្លាប់ឮតែពីគំនិតក្នុងសាលាប៉ុណ្ណោះ និង ពួកគេព្យាយាមយកអស់ទាំង—ព្រះពររបស់ព្រះ និង ដាក់វានៅតាមថ្ងៃដែលកន្លងផុត។

93 អ្នកអធិប្បាយបាបទីស្តវ៍យក្មេងម្នាក់ នៅទីនេះមិនយូកន្លងទៅឡើយ អង្គុយមានវត្តមាននៅព្រឹកនេះនិងបានមកជួបខ្ញុំនិងនិយាយ"បងប្រុសប្រានហាំ មានរឿង មួយដែលអ្នកកំពុងតែខុស។"

ខ្ញុំនិយាយថា "ជួយខ្ញុំផង។"

94 ហើយគាត់និយាយថា "អ្នកគឺខ្ញុំគិតថាអ្នកស្មោះត្រង់និងជាមនុស្សល្អ ប៉ុន្តែ..."

ខ្ញុំនិយាយថា "អគុណ លោក។"

គាត់និយាយថា "ប៉ុន្តែមានរឿងមួយអ្នកកំពុងតែខុស។"

ខ្ញុំនិយាយ "ខ្ញុំសង្ឃឹមថាព្រះអម្ចាស់នឹងរកបានអ្វីមួយដែលខុស។"

95 ហើយគាត់និយាយថា "ល្អ មាន...នេះជាអ្វីដែលអ្នកខុស។" និយាយ "អ្នកព្យាយាមណែនាំពិភពលោកពីពន្ធ័កិច្ចសាវក និង" និយាយ "ពន្ធ័កិច្ចសាវកបានចប់ជាមួយពួកសាវកហើយ។"

96 ខ្ញុំនិយាយ "ភាពជាបាបទីស្តទល់នឹងបាបទីស្ត ខ្ញុំចង់សួរអ្នកនូវសំណួរមួយ។"

និយាយ "អ្វី?"

97 ខ្ញុំនិយាយ "អ្នកជឿថា ព្រះបន្ទូលរបស់ព្រះ គឺត្រូវបានបណ្តាលឲ្យសរសេរឡើង រាល់ក្បៀសនៃពាក្យ?"

គាត់និយាយ "ហេតុអ្វី ជាការពិត។"

98 ខ្ញុំនិយាយ "ដូច្នេះ ទ្រង់មានបន្ទូល 'កុំបន្ថែមពាក្យណាមួយ ឬដកពាក្យណាមួយ' ព្រោះ" ខ្ញុំនិយាយត "ខ្ញុំនឹងបង្ហាញអ្នកត្រង់កន្លែងព្រះពររបស់ពួកសាវកបាន មក ដល់មនុស្ស ដោយសេចក្តីសន្យារបស់ព្រះ ឥឡូវអ្នកបង្ហាញខ្ញុំពីសេចក្តីសន្យារបស់ព្រះ និង ពេលដែលវាទៅផុតមនុស្សដែរ។ មើល បើអ្នកមិនអាចបង្កើតពីការនោះតាមរយៈព្រះបន្ទូល ដូច្នេះ—ដូច្នេះ បំភ្លេចវាចុះ" ខ្ញុំនិយាយ "ពីព្រោះវានៅតែ បន្ត។"

99 គាត់មិននិយាយអ្វីពីរបីនាទី។ ហើយខ្ញុំនិយាយ "ល្អ ដូច្នេះ បងប្រុស ខ្ញុំចង់សួរអ្នករឿងនេះ។ ពេត្រុសណែនាំ ពីសារសាវក នៅថ្ងៃបុណ្យទី៥០។ ហើយយើងដឹងថាវាជាសេចក្តីពិត ព្រោះគាត់មានកូនសោរនៃនគរស្ថានសួគ៌ ដែលព្រះយេស៊ូវបាន

ប្រទានមក។ ហើយឥឡូវពិនិត្យមើលអ្វីដែលគាត់និយាយ។ គាត់និយាយ“ប្រែចិត្តចុះ គ្រប់គ្នានៃអ្នក និង ជ្រមុជទឹកក្នុងនាមព្រះយេស៊ូវគ្រីស្ទសម្រាប់ការសងថ្លៃបាប ហើយ អ្នកនឹងទទួល អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។ ព្រោះសេចក្តីសន្យាចំពោះអ្នក និង កូនចៅរបស់អ្នក និង ដល់អ្នកដែលនៅតទៅទៀត ទោះជាច្រើនយ៉ាងណាដែលព្រះអម្ចាស់ជាព្រះរបស់យើងនឹងត្រាស់ហៅ “ដូច្នេះបើមានកន្លែងណាដែលទ្រង់ដកចេញ ដូច្នេះតើនឹងមានអ្វីកើតឡើង ចំពោះពាក្យរបស់ពេត្រុសនៅថ្ងៃបុណ្យទី៥០?” ឃើញ? ទេ វាមិនដែលបញ្ចប់ឡើយ!

កូនចៀមដែលជិតស្លាប់ជាទីស្រលាញ់លោហិតដ៏មានតម្លៃ
នឹងមិនដែលបាត់អំណាចចេស្តាឡើយ
រហូតដល់ក្រុមជំនុំដែលសងថ្លៃលោះរបស់ព្រះ
បានសង្គ្រោះ មិនមានបាបទៀតឡើយ។

ដូច្នេះក្នុងភាពខ្ពង់ខ្ពស់ ចម្រៀងផ្អែមល្ហែម
ខ្ញុំនឹងច្រៀងពីអំណាចចេស្តាទ្រង់ដែលសង្គ្រោះ
ពេលដែលសម្លេងឡលៗដ៏កំសត់ អណ្តាតត្រដិត
ផ្តេកយ៉ាងស្ងាត់នៅក្នុងផ្នូរ។

100 ព្រះជាម្ចាស់បានជួយខ្ញុំឲ្យជឿការនោះ និង ចាប់វាយ៉ាងជាប់ហើយយើងទាំងអស់គ្នានិង ឈរលើសេចក្តីនោះ ព្រោះវាជាសេចក្តីពិតនៃដំណឹងល្អ! បាទលោក។

101 មនុស្សឆ្លាត មិនគួរនឹងមើលចំនុចនេះឡើយ។ ហើយដឹងថា វាមិនដំណើរការឡើយ។ ពួកវាមិនដំណើរការឡើយ។ សាសនាដែលរៀបចំឡើងនិងបទពិសោធន៍ដែលរៀបចំឡើងមិនដំណើរការក្នុងវត្តមានរបស់ព្រះជាម្ចាស់ឡើយ។ វាត្រូវតែមកពីព្រះជាម្ចាស់ មិនមានការលាយឡំ។ វាមិនត្រូវបានប្រើដោយព្រះជាម្ចាស់ឡើយគ្មានសម័យណាមួយក្នុងអតិតកាល ដែលព្រះប្រើប្រព័ន្ធបែបនោះឡើយ។ ឥឡូវអ្នក អូអ្នកមានសមាជិកនិងអ្វីបែបនោះ។ ប៉ុន្តែខ្ញុំចង់និយាយពីគ្រាប់ពូជពិតប្រាកដនៃព្រះជាព្រះពរដែលធ្លាក់មកនៅថ្ងៃបុណ្យទី៥០ វាមិនមែនមកដោយអង្គការឡើយ វាបានមកដោយកំណើតកើត ការកើតជាថ្មី។

102 យើងត្រូវបានអញ្ជើញឲ្យយកអ៊ីស្រាអែលជា—ជាឧទាហរណ៍ ដែលពួកគេធ្លាប់ធ្វើមក។ កត់ចំណាំ “ពួកគេបានបោះបង់ទ្រង់ចោល ជាប្រភពទឹកផុត់ផុង

របស់ពួកគេ និង បានជីកកាប់អាងទឹកមួយសម្រាប់ខ្លួនឯង" តើអ្នកអាចស្រមៃពី—ពី—ពី—រឿងនោះពេលមនុស្សម្នាក់នៅអណ្តូងជ្រៅផឹកទឹកហើយចង់ជីក អាងមួយ ផ្ទាល់ខ្លួន ឃើញ ផឹកពីអាងទឹក? ឥឡូវនេះជាអ្វីដែលព្យាការីបាននិយាយ នោះជាអ្វីដែលព្រះបន្ទូលបាននិយាយ។ នោះជាអ្វីដែលព្រះមានបន្ទូលជាមួយព្យាការី។ "អ្នកបានបោះបង់យើងចោល និង—និង ចាកចោលយើង ជាប្រភពទឹករស់ និង ជីកកាប់អាងទឹកមួយសម្រាប់ខ្លួនឯង ដែលជាអាងប្រេះបែកនិង ពួកវាបានលិច។"

103 ឃើញ មានអ្វីមួយពួកគេត្រូវការអ្វីមួយ ពួកគេអាចគ្រប់គ្រង ឬ បង្ហាញអ្វីដែល ពួកគេបានធ្វើ។ នោះគឺ—នោះគឺសាសនាដែលត្រូវបានរៀបចំឡប់ៗ។ វាតែងតែព្យាយាមពួកគេមានអ្វីមួយនៅក្នុងនោះដោយខ្លួនផ្ទាល់។ ពួកគេត្រូវមានប្រព័ន្ធទាំងអស់នេះនិងសង្គមនេះនិង អ្វីមួយ "ហើយ ខ្ញុំជាកម្មសិទ្ធ *នេះ* នាពេលឥឡូវ។" ជំនួសឲ្យការបន្ទាបខ្លួនជាបុត្ររបស់ព្រះ ពួកគេចង់បានអ្វី ដែលពួកគេអាចបង្ហាញខ្លួនឯង។ ជំនួសឲ្យព្រះជាម្ចាស់ធ្វើការនោះតាមរបៀបរបស់ទ្រង់ ពួកគេចង់ធ្វើតាមរបៀបរបស់ពួកគេ។ ហើយនោះជារបៀប ដែលប្រព័ន្ធមានក្នុងក្រុមជំនុំសព្វថ្ងៃ។ មិន...ប្រព័ន្ធនីមួយៗ មនុស្សម្នាក់ចង់បានវារបៀប*នេះ* មនុស្សម្នាក់ចង់បានវារបៀប*នោះ*។ បើអ្នកជាមេតូឌីស្ត អ្នកត្រូវតែតាមរបៀប*នេះ*។ អ្នកបាបទីស្ត តាមរបៀប*នេះ*។ ព្រីសប៊ីធីរៀន កាតូលិក អ្វីក៏ដោយ ពួកគេមានប្រព័ន្ធរបស់ពួកគេ។ គ្មានអ្វីទាស់នឹងរឿងនោះទេឡើយ ប៉ុន្តែនោះមិនមែនជាអ្វីដែលខ្ញុំកំពុងនិយាយឡើយ។

104 មនុស្សចង់បានរបៀបរបស់ខ្លួនក្នុងការធ្វើវា ហើយ ព្រះជាម្ចាស់មានរបៀបរបស់ទ្រង់ក្នុងការធ្វើវា។ ហើយទ្រង់មានបន្ទូលថា "អ្នកកំពុងក្តោបកាន់ផ្លូវរបស់ខ្លួនគឺជាអាងប្រេះបែក និង មិនទទួលផ្លូវរបស់យើង ដែលជាផ្លូវនៃជីវិត។"

105 ហើយ វាក៏ដូចជារបៀបនាសព្វថ្ងៃនេះដែរ។ វាមិនមានអ្វីខុសគ្នាបន្តិចឡើយ។ សូមគិតពីភាពល្ងង់របស់មនុស្សដែលចេញពីអណ្តូងទឹកជ្រៅដែលថ្លា និងមានទឹកផុសមក ហើយគាត់បែជាចង់ទៅរកអាងទឹកដែលប្រេះបែកដែលធ្វើឡើងដោយខ្លួនឯង ហើយ ជីកអាងទឹក ដែលមានសម្រាមពីលើដែលចេញមកពីការលាងដំបូលជង្រុកស្រូវ រួចក៏ផឹកទឹកនោះ។ មានអ្វីមួយដែលខុសដោយរោគចិត្តហើយជាមួយមនុស្សម្នាក់នោះ។

106 ហើយ ពេលមនុស្សតោងយក—ទស្សនៈពីសាស្តានៅក្នុងខគម្ពីរ ជាសជាង ទទួលយកព្រះវិញ្ញាណបរិសុទ្ធដែលកាត់សេចក្ដីពីខគម្ពីរ និង ធ្វើឲ្យវាបានក្លាយជាការពិតសម្រាប់អ្នក មានអ្វីមួយដែលខុសខាងឯវិញ្ញាណ សម្រាប់មនុស្សបែបនោះ។ វាជាការពិត។ ប្រាកដណាស់ ព្រះវិញ្ញាណបរិសុទ្ធ! មនុស្សម្នាក់ៗមានការបកស្រាយក្នុងគម្ពីររបស់ពួកគេ អ្វីអ្នកគិតគឺត្រឹមត្រូវ។ ព្រះជាម្ចាស់ មិនត្រូវការអ្នកជួយឡើយ។ ព្រះជាម្ចាស់មិនត្រូវការ ការបកស្រាយរបស់អ្នកឡើយ។

107 ព្រះជាម្ចាស់គឺជាអ្នកបកស្រាយផ្ទាល់វិញ។ ព្រះជាម្ចាស់ ធ្វើការបកស្រាយតាមរបៀបទ្រង់—របៀបទ្រង់មានបន្ទូល ទ្រង់នឹងធ្វើវា។ ព្រះជាម្ចាស់ មានបន្ទូលពីដំបូងមក"ចូរមានពន្លឺ"នោះក៏មានពន្លឺ។ នោះគឺមិនត្រូវការការបកស្រាយអ្វីឡើយ។ នោះជាអ្វីដែលទ្រង់បានធ្វើ។ ទ្រង់មានបន្ទូល "ស្រីក្រមុំ នឹងមានផ្ទៃពោះ" នាងមានមែន។ នោះមិនត្រូវការ ការបកស្រាយអ្វីឡើយ។ ទ្រង់មានបន្ទូលថា ទ្រង់នឹង"ចាក់វិញ្ញាណទ្រង់លើសាច់មានជីវិត" ទ្រង់បានធ្វើ។ វាមិនត្រូវការការបកស្រាយ អ្វីឡើយ។ ព្រះជាម្ចាស់បកស្រាយព្រះបន្ទូលទ្រង់ដោយកាត់សេចក្ដីត្រឹមត្រូវចំពោះ វា និង បើកសម្ដែងឲ្យឃើញ និង បង្ហាញវា។

108 នោះជាអ្វីដែលព្យាការីត្រូវបានបង្ហាញថាមកពីព្រះ។ ទ្រង់មានបន្ទូលថា "បើមាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នា ជាអ្នកមានវិញ្ញាណ ឬជា ព្យាការី យើងជាព្រះអម្ចាស់នឹងបង្ហាញខ្លួនឲ្យគាត់បានស្គាល់តាមរយៈនិម្មិត និយាយទៅកាន់គេតាមរយៈយល់សប្តិ។ ហើយអ្វីដែលគាត់និយាយ យើងបានសម្រេច ដូច្នេះកោតខ្លាចគាត់ចុះ ប៉ុន្តែបើវាមិនសម្រេចកុំកោតខ្លាចឡើយ"។

109 នោះដូចគ្នាពេលព្រះមានបន្ទូលរបស់ទ្រង់ ហើយមនុស្សនិយាយ "ព្រះបន្ទូលគឺបែប*នេះ*" និង វាកើតឡើងរបៀបនោះ ដូច្នេះវាគឺជាព្រះហើយដែលធ្វើវា។

110 ប៉ុន្តែបើគាត់និយាយ "វាគឺបែប*នេះ* ហើយថ្ងៃចេះតែកន្លងទៅ" ហេតុអ្វីបានជាវាយកអស់ទាំង...ទ្រង់ហុចនំបុ័ងដែលគេឃ្លាន នៅក្នុងដៃ ដល់ក្មេងៗ និង យកចេញពីគេវិញ ហើយ ពួកគេឃ្លានយ៉ាងខ្លាំង។ ហេតុអ្វីអ្នកចង់ផឹកទឹកចេញពីអាងទឹក កាលបើអណ្តូងទឹកជ្រៅនៅទីនោះ?

111 អ្វីជាប្រភពទឹកជីវិតនាឥឡូវនេះ? អ្វីជាប្រភពទឹកនៃជីវិត ជាប្រភពទឹករស់? អណ្តូងទឹកជ្រៅ យើងនឹងប្រដូចវា។

112 ឥឡូវខ្ញុំចង់ឲ្យអ្នកកត់សម្គាល់ពីភាពខុសគ្នារវាងអាងទឹក និង ប្រភពទឹករស់ អណ្ដូងជ្រៅ និងអាងទឹកចាស់ដែលមានពេញដោយ សត្វស្លាបល្អិតៗ ជីងចក់ កង្កែប មេរោគ និងអ្វីទៀត ឃើញ។

113 ហើយទីនេះជាអណ្ដូងទឹកជ្រៅ។ ឥឡូវ មើលរឿងនេះ។ វាជាការជួយខ្លួនឯង។ អ្នកមិនចាំបាច់មានប្រព័ន្ធមួយធំ និង នាំលុយជាច្រើនចូលក្នុងនោះឡើយ។ អ្នកមិនចាំបាច់មានសមាជិក ចូលរួមច្រើននោះទេ។ វាបានជួយសមាជិក របស់វា វិញ្ញាណនៃជីវិតនៅក្នុងពួកគេ ជាអ្នកធ្វើតួនាទី។

114 ចំណាំ ទឹកដែលចេញពីវា ស្រស់ សុទ្ធ និង ស្អាត។ មិនមែនជា អាង ដែលមានអ្វីជាប់កខ្វក់ចងក្រងជាឯកសារពី ៤០ទៅ ៥០ដែលមានគំនិតខុសៗគ្នា រួចនិយាយថា "*នេះ*គឺត្រូវ *នោះ*គឺត្រូវ និង ទស្សនៈ*នេះ*" ហើយបោះឆ្នោតហៅមក និងដូចពួកគេធ្វើនិងបង្កើតនិកាយមួយចេញពីនោះ។ វាជាភាពសុទ្ធនិង ស្អាតជាព្រះបន្ទូលសុទ្ធ ចេញពីព្រះហស្តទ្រង់។ វាជាអណ្ដូងទឹកជ្រៅដែលពិត។

115 កត់សម្គាល់ អាថ៌កំបាំងនៃអំណាចរបស់វា គឺនៅក្នុងនោះ។ មនុស្សមិនអាចរកវាឃើញឡើយ។ ជាប្រភេទនៃសម្ពាធ ខាងក្រោមវាដែលធ្វើឲ្យវារុញមក។

116 ខ្ញុំចងចាំពេលខ្ញុំ ធ្លាប់ ជាឆ្នាំហ្គេមនៅអិនឌៀអាយណា។ ខ្ញុំធ្លាប់ចេញទៅ ក្នុងហារីសាន់ ខោនធី មានអណ្ដូងមួយ ជារន្ធទឹក។ វាតែងតែផុសចេញទឹកមក។ ហើយគ្រាន់តែជាអូ វាមើលទៅដូចជាអ្វីមួយដែលរីករាយបំផុត។ មិនថាមាន ព្រិលនៅលើដី ទឹកកក មានការបង្កក តើវាយ៉ាងណាដែរ វានៅតែចេញទឹកមក កន្លែងដែលមនុស្សចាស់ៗធ្វើស្រះ ឬ អាងមនុស្សបង្កើតអមដោយកង្កែបនឹងគ្រប់ យ៉ាងបានក្លាយជាកករឹង។

117 ហើយនោះជាការបង្ហាញថា និកាយណាក៏ដោយ តាមរយៈការខ្វះវិញ្ញាណឬការផ្លាស់ប្ដូបន្តិចនៃបរិយាកាស នឹងត្រូវកកហើយ។ ប៉ុន្តែ អណ្ដូងទឹកជ្រៅរបស់ព្រះជាម្ចាស់ ទ្រង់—ទ្រង់នៅដូចថ្ងៃម្សិលមិញ ថ្ងៃនេះ និងរហូតទៅ វានៅតែបន្តផុសពពុះទឹកចេញមក។ ហើយគ្មានអ្វីអាចចាប់ផ្ដើមលើវាបានទេ។ ហើយពេលមានអ្វីចូលទៅ វានឹងរុញចេញពីផ្លូវនោះ។

118 នោះជាអ្វីដែលផុសចេញមកបែបនោះហើយ ខ្ញុំនិយាយ អង្គុយនៅទីនោះមួយថ្ងៃខ្ញុំគិត "ខ្ញុំជឿខ្ញុំនឹងចង់និយាយជាមួយរន្ធទឹកនោះ មួយភ្លែត" ខ្ញុំ

ដោះមួកចេញ រួចនិយាយថា "តើអ្នកសប្បាយរីករាយអំពីអ្វី? តើអ្នកផុសទឹកចេញមកដើម្បីអ្វី? ប្រហែលជាមាន សត្វក្ដាន់ផឹកទឹកចេញពីអ្នកហើយ យូៗម្ដង។"

បើគាត់អាចនិយាយបាន គាត់នឹងឆ្លើយថា "ទេ។"

ខ្ញុំនិយាយ "ប្រហែល វាដោយសារខ្ញុំផឹកពីអ្នក។"

"ទេ នោះមិនមែនដូច្នេះទេ។"

119 ខ្ញុំនិយាយ "ល្អ អ្វីធ្វើឲ្យអ្នកក្លាយជាសុទ្ធណាស់ និង ស្អាតណាស់? ដូច្នេះអ្វី—អ្វីដែលផុសផុលមកដែលធ្វើឲ្យអ្នកផុសផុល ពេញដោយអំណរគ្រប់ពេល និង គ្មានអ្វីអាចបង្អកអ្នកបាន? អ្នកកំពុងបាញ់ចេញទៅក្នុងអាកាស ហើយគ្មានអ្វី ក្រៅពីទឹកស្អាត។

120 បើសិនជាវាអាចនិយាយមកកាន់ខ្ញុំបាន អ្នកដឹងហើយថា អ្វីដែលអណ្ដូងនឹងនិយាយ? គាត់អាចនិយាយ "បងប្រុសប្រានហាំ វាមិនមែនជាខ្ញុំទេ ដែលផុសផុល វាមានអ្វីនៅពីក្រោយខ្ញុំ ផុសផុលក្នុងខ្ញុំ" និង ជារបៀបនោះ។ នោះជាពាក្យដ៏កំសត់ ប៉ុន្តែអ្នកដឹងពីអត្ថន័យរបស់ខ្ញុំហើយ។

121 ហើយនោះជារបៀបនៃបទពិសោធន៍ការកើតជាថ្មី។ អ្នកមិនអាចមានវាបានឡើយ។វាជា—អណ្ដូងទឹកនៅក្នុងអ្នកផុសផុលចេញមកជាជីវិតអស់កល្ប។ ឃើញមានអ្វីពីវា អ្នកមិនចាំបាច់ធ្វើអ្វីជាមួយវាឡើយ។ អាងធ្វើដោយមនុស្សអាចនឹងកក ហើយ ពួកវាអង្វររកការផុសផុល និង គ្រប់យ៉ាង ប៉ុន្តែមនុស្សដែលស្ថិតនៅក្រោមប្រភពទឹកនោះ រស់នៅក្នុងប្រភពទឹកនោះ ទាំងថ្ងៃទាំងយប់! ទេ អ្នកមិនត្រូវរង់ចាំរហូតដល់មានភ្លៀងក្នុងតំបន់ ឬ ការចាក់ព្រះចេស្ដាក្នុងតំបន់ឡើយ។ អ្នកមានពេញដោយវារួចហើយ។ "ខ្ញុំនឹងឲ្យទៅគាត់នូវប្រភពទឹកជីវិត ក្នុងគាត់មានកាផុសផុលឡើង។" មានអ្វីមួយក្នុងនោះ ដែលស្រស់ថ្មីជារៀងរាល់ថ្ងៃសុទ្ធ និង ស្អាត។ វាគឺជាព្រះបន្ទូលព្រះដែលមិនមានការលាយឡំ នៅក្នុងចិត្ត និង មាត់បានបង្ហាញថាត្រឹមត្រូវខ្លួនវា និយាយសម្រាប់ខ្លួនវាផ្ទាល់។ ខ្ញុំមិនខ្វល់ពីថាមានភ្លៀងឬក៏អត់ ថាមានព្រិលឬអត់ អាកាសធាតុជាបែបណាទេ អ្នកនៅតែរីករាយ ព្រោះព្រះវិញ្ញាណបរិសុទ្ធនៅក្នុងបានផុសផុលមក។វាជាអំណោចដែលលាក់ទុក។ សូមកត់សម្គាល់។ អូ វាមានអាថ៌កំបាំងនៅក្នុងនោះ។

122 វាបានផ្តល់ឲ្យខ្លួនវា សេរីភាព ដល់អស់អ្នកដែលនឹងផឹក និង ប្រើសារធាតុរបស់វា។ ឥឡូវអ្នកកុំច្បាមចេញនិយាយ "ល្អ ឥឡូវខ្ញុំគ្រាន់តែទៅក្រុមជំនុំមេតូឌីស្ត ព្រោះខ្ញុំជាមេតូឌីស្តដើម្បីទទួលបានការចាក់ព្រះចេស្តា។ ខ្ញុំត្រូវទៅកន្លែង*នេះ* ប៉ុន្តែ (បើ)ខ្ញុំត្រូវទៅរកពេនតេកុសព្រោះខ្ញុំជាអ្នកមានការចាក់ព្រះចេស្តារបស់ពេនតេកុស ។" ខ្ញុំនឹងប្រាប់អ្នកថា ពេលអ្នកមានអណ្តូងទឹកដែលមានទឹកផុស ចេញពីប្រភព នោះ ពេលអ្នកផឹកវាមិនមានភាពខុសគ្នាឡើយ អ្នកអាចឲ្យអ្វីក៏បានដែលមកជិត។ អ្នកនឹងមានឆន្ទៈក្នុងការផ្តល់នូវក្តីសង្ឃឹមនៃជីវិតទៅដល់កាតូលិក ទៅប្រូតេសស្តង់ ទៅពួកយូដាទៅអ្នកមិនជឿថាមានព្រះឬអ្វីក៏ដោយ។ អ្នកពិតជា ពិតជាមានអ្វីក្នុង អ្នក ដែលធ្វើ។

123 អ្នកកត់សម្គាល់អ្វីមួយទៀតអំពីវា អ្នកមិនចាំបាច់បូមឡើងទេ។ អ្នកមិនបាច់ទាញវាមកទេ និង បូមឡើងទេ។ ខ្ញុំឃើញច្រើនណាស់ពីរឿងនោះរហូតដល់វាធ្វើឲ្យខ្ញុំឈឺបូមអ្វីមួយលេងតន្ត្រីមួយសំណុំលោតចុះ-និង-លោតឡើងឬ—ឬមាន សំណុំអក្សរសាស្ត្រនៅក្នុងក្រុង និង សញ្ញាធំៗ "បុរសនៃពេលវេលា។"

124 មានមនុស្សតែម្នាក់នៃពេលវេលាហើយ នោះគឺព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់នៅដូចថ្ងៃម្សិលមិញថ្ងៃនេះនិងរៀងរហូតទៅ។ មានអ្នកនាំសារតែមួយពីព្រះជាម្ចាស់ហើយនោះគឺ—នោះគឺព្រះយេស៊ូវគ្រីស្ទ។ ហ្នឹងហើយ។

125 អ្នកមិនចាំបាច់បូមវាឡើង ឬ ទាញវាទម្លាក់ចុះឡើយ។ ឬ មិនទាំង អ្នកមិនចាំបាច់ចូលរួមជាមួយវាផង។ អ្នកគ្រាន់តែយកវាមក ដោយឥតគិតថ្លៃ។ អាម៉ែន។ "ខ្ញុំជាប្រភពទឹករស់ អ្នកចាកចេញពីខ្ញុំ ដើម្បីបង្កើតអាងមួយសម្រាប់ខ្លួន។" ឥឡូវអ្នកមិនចាំបាច់បូមវាឡើងបូមវា ទាញវានិង ចូលរួមជាមួយវា ជីកវា គ្មានអ្វីឡើយ។ អ្នកគ្រាន់តែយកវាមក ដោយឥតគិតថ្លៃ។

126 អ្នកមិនត្រូវការទេវវិទ្យាដែលមនុស្សបានបង្កើតឡើយ ដើម្បីធ្វើជាកន្ទបតម្រងក៏មិនចាំបាច់ ប្រាប់អ្នកពីអ្វីត្រូវឆ្លងកាត់វាដែរ អ្វីដែលវាធ្វើ។ គ្មានឡើយ។ ទេវវិទ្យាដែលមនុស្សបានបង្កើតនៃប្រព័ន្ធការសិក្សាអប់រំខ្លះ សាសនាសុចរិតដោយខ្លួនឯងនៅក្នុង*នេះ*ត្រង់*នេះ* ឬ អាងខ្លះនៃប្រព័ន្ធសាសនា អ្នកមិនចាំបាច់ត្រូវការពួកវាទេ។ វាមិនចាំបាច់មាននៅទីនោះឡើយ។ អ្នកដាក់កន្ទបពីលើ វាបាញ់ខ្សែត្រង់ទៅលើអាកាស។ វាមិនមានអ្វីដែលត្រូវធ្វើជាមួយវាឡើយ។ វាអាចជួយខ្លួនវាបាន! វាជាព្រះចេស្តានៃព្រះជាម្ចាស់ ផុសចេញឡើងជាជីវិត។ ហេតុអ្វីបានជា

មនុស្សចាកចេញពីអ្វីមួយបែបនោះ រួចទៅចូលរួមប្រព័ន្ធ គឺច្រើនជាងអ្វីដែលខ្ញុំអាចនិយាយ។ ខ្ញុំមិនត្រូវការកន្ទបតម្រងណាមួយឡើយ។ វាមិនចាំបាច់។ វាមិនចាំបាច់មានភាពបែបនោះ មិនចាំបាច់ពឹងភ្លៀងតំបន់ដែលធ្លាក់មក។ វាបានពេញគ្រប់ពេល។ អាម៉ែន។

127 មនុស្សម្នាក់ ខ្ញុំឮពួកគេនិយាយ "ខ្ញុំទើបតែធ្លាក់ក្នុងគំនរសម្រាមនៅថ្ងៃនេះ" អូ ខ្ញុំអើយ!

128 អូ ខ្ញុំរីករាយក្នុងការរស់នៅក្នុងវត្តមាននៃព្រះជាម្ចាស់ មិនថាវាត្រូវ ឬក៏ខុសនោះទេ។ ទ្រង់ជាជីវិតរបស់ខ្ញុំ។ អាម៉ែន។ ទ្រង់ជាជីវិតរបស់យើង។ អាម៉ែន។ ទ្រង់គឺជាជីវិត ទ្រង់ជាជីវិតជាជីវិតពេញបរិបូរណ៍។ ហ្នឹងហើយ។ ហើយ—ហើយ មើលអ្វីដែលទ្រង់ធ្វើសម្រាប់យើង។ អំណាចរបស់វា និង ភាពបរិសុទ្ធរបស់វាគឺនៅក្នុងវាផ្ទាល់។ វាមិនចាំបាច់ទទួលការប្រៀនប្រដៅពីអាងទឹក ឬ ប្រព័ន្ធណាឡើយ។

129 មានអ្នកខ្លះនិយាយថា "ល្អ ចុះកាតប្រកបគ្នារបស់អ្នកវិញ? មើលទៅមើលថាតើអ្នកជាអ្នកបាបទីស្ដល្អ។ ខ្ញុំនឹងមើលបើអ្នកមានកាត។ ឬ—ឬ អ្នកពេនទីកុស្ដល្អបើអ្នកមានភាពតែមួយ ភាពពីរ ភាពបី ឬ—ឬអ្វីផ្សេងទៀត" ឃើញ វាមិនចាំបាច់ទទួលការបង្ហាត់ទេ។ វានៅតែបន្តទៅមុខ។ ហ្នឹងហើយ។

130 អ្នកដឹងទេ ខ្ញុំធ្លាប់មានអាងចាស់នេះ ខ្ញុំត្រូវចាក់ទឹកចុះទីនោះរៀន និង រៀន និង រៀនជាមួយបំពង់បូមចាស់នេះ ដើម្បីចេញពីនោះ អ្នកដឹងទេ ចាក់ទឹកថែមទៅក្នុងនោះ និងគ្រាន់តែជាការចាក់សំណុំសត្វល្អិតមានស្លាប និង អ្វីទៅក្នុងប៉ុណ្ណោះ ដើម្បីបូមបាន សត្វស្លាបល្អិតនិងអ្វីៗ។ នោះជារបៀប នៃការចាក់ព្រះចេស្ដាជាប្រព័ន្ធ។

131 ប៉ុន្តែ អរគុណព្រះជាម្ចាស់ "មានប្រភពទឹកពេញដោយលោហិត ដែលមនុស្សបាបជាប់ ពីក្រោមលោហិត" អ្នកមិនបង្កើតសមាជិកក្រុមជំនុំទេ អ្នកបង្កើតគ្រីស្ទានចេញពីនោះវិញ កាលបើគេចូលមកប្រភពទឹកនោះ។

132 ហេតុអ្វី បានជាអ្នកចាកចេញពី ប្រភពទឹករស់រួចទៅផឹកនៅអាងទឹកស្អុយដូច្នេះ?

133 មិនបាច់បូមឡើង អំណាចរបស់វាមាននៅក្នុងវាផ្ទាល់។ វាមិនចាំបាច់បង្ហាត់បង្រៀនទេ ហ្នឹងហើយព្រោះ(វាផ្ទាល់)ជីវិតវាផ្ទាល់នៅក្នុងវា។ នោះគឺជា

គ្រាប់ពូជនៃព្រះមាននៅក្នុងចិត្តរបស់មនុស្ស។ ព្រះជីវិតរបស់ព្រះមាននៅក្នុងបុគ្គលម្នាក់ៗ មិនមែនក្នុងក្រុមជំនុំឡើយ។ ក្នុងអ្នក វានៅក្នុងអ្នក អ្នកជាម្នាក់ដែលមានសរីរាង្គជីវិតក្នុងអ្នក។

134 គ្រាន់តែរសជាតិមួយ នៃការបញ្ចុះបញ្ចូលដល់អស់ទាំងស្មៀន។ សួរសង្ឃកាតូលិកសួរអ្នកបាបទីស្ត អ្វីក៏ដោយ។ គ្រាន់តែជារសជាតិមួយនៃទឹកស្រស់ថ្លាដ៏អស្ចារ្យ ខ្ញុំកំពុងប្រាប់អ្នក វាបញ្ចុះបញ្ចូលថា នោះជាសេចក្តីពិត។ ព្រលឹងស្រេកឃ្លានរបស់អ្នកទោះជាយ៉ាងណាវាបានបញ្ចុះបញ្ចូលអ្នកទៅកាន់ ការស្រេកទឹក ទោះរបៀបណាក៏ដោយ។ ឥឡូវបើអ្នកមិនស្រេក...បាបទីស្តតូចមួយនេះ គាត់មិនស្រេកពីដំបូងប៉ុន្តែពេលគាត់ស្រេកទឹកមានរសជាតិឆ្ងាញ់ណាស់។ នោះជាការត្រឹម ត្រូវប៉ុន្តែអ្នកត្រូវតែស្រេក "ជាការស្រេក ដ៏មានពរ" ដូចព្រះយេស៊ូវបានហៅ "មានពរហើយអស់អ្នកដែលពិតជាស្រេកឃ្លានសេចក្តីសុចរិត ព្រោះអ្នកនឹងបានឆ្អែត" ហើយព្រះយេស៊ូវមានបន្ទូលថាជាមិត្តសម្លាញ់។ ហ្នឹងហើយ វាជាប្រភពទឹកមានពរដល់អស់អ្នកដែលស្រេក។

135 ហេតុអ្វីបានជាមានអ្នកចង់ប្តូរវាទៅយកវាលភកវិញ?តើអ្នកប្តូរអណ្តូងទឹកជ្រៅយកទឹកភកវិញ ដែលពេញដោយសត្វល្អិតយ៉ាងដូចម្តេច ហើយ ភាពកខ្វក់នៃគ្រប់ ទាំងប្រភេទទ្រឹស្តីបង្កើតដោយមនុស្សហើយព្រះមានបន្ទូលថា "កាបន្ថែមពាក្យមួយ ទៅក្នុងព្រះបន្ទូលទ្រង់ ឬ យកពាក្យមួយចេញពីព្រះបន្ទូលចំណែករបស់អ្នកនោះនឹងត្រូវបានដកចេញពីសៀវភៅជីវិតដែរ"?

136 ហើយ ពេលព្រះសន្យាថាទ្រង់នឹងកាត់សេចក្តីត្រឹមត្រូវព្រះបន្ទូលនេះគ្រប់ទាំងជំនាន់ "ព្រោះសេចក្តីសន្យាសម្រាប់អ្នក និង កូនចៅរបស់អ្នក និង សម្រាប់ពួកគេតទៀតតាមតែចំនួនដែលព្រះអម្ចាស់ជាព្រះរបស់យើង ត្រាស់ហៅ" ហេតុអ្វីបានជាអ្នកបូមពីបំពង់ប្រព័ន្ធដែលកខ្វក់មកយូឆ្នាំ តាំងពីនំម៉ាណាចាស់? ប្រហែលជានំម៉ាណាមិនមានបញ្ហាទេ គ្មានអ្វីទាស់នឹងវាទេ ក្នុងសម័យម៉ាធីនលូធឺ ក្នុងសម័យ*នេះ* និងសម័យ*នោះ* និង អ្នកបំផ្លាស់បំប្រែផ្សេងទៀត គ្មានអ្វីជាមួយនឹងពួកវាទេ ប៉ុន្តែ នំម៉ាណានោះធ្លាក់មកជាយូឆ្នាំហើយ។

137 បើយើងកត់សម្គាល់ពីព្រះគម្ពីរ ដែលយើងយកវាមកអានជារៀងរាល់ថ្ងៃ។ ពួកវាត្រូវតែមានអ្វីថ្មី។ បន្ទាប់ពីវាចាស់បន្តិច វានឹងពុក។ វាមិនអាចពុកដោយគ្មាន

ការបែកនោះឡើយ។ វាត្រូវតែមានបាក់តេរីក្នុងនោះ ឬអ្វី—ធ្វើឲ្យវាពុក។ យើងដឹងថាវា ដូច្នេះ។

138 ហើយ ដូច្នេះក្នុងប្រព័ន្ធ! បន្ទាប់ពីវាបានដណ្ដប់ដោយការរីកផុសផុលយ៉ាងធំទៅគ្នាទៅវិញទៅមក វានឹងក្លាយជាកខ្វក់និង ពេញដោយសត្វស្លាបល្អិតៗ និងប្រៀបដូចជាអាងទឹក មានពេញដោយកន្ទុយខ្ញីកៗ ដែលយើងធ្លាប់ហៅ វាថាសត្វស្លាបល្អិតៗកន្ទុយខ្ញីកៗនៅក្នុងនោះ។

139 ហើយ នោះជាបទពិសោធន៍មនុស្សជាច្រើននៅសព្វថ្ងៃ។ ពួកគេ—ពួកគេពេញដោយសត្វល្អិតកន្ទុយខ្ញីកៗបម្រះរវើកៗ ពីមួយទៅមួយប្រាប់រឿងដែលមិនមាន សេចក្ដីពិតក្នុងនោះទាល់តែសោះ។ ជាការពិត បម្រះចេញពីមួយទៅមួយ។ "ខ្ញុំពីមុនជាមេតូឌីស្ត ខ្ញុំចូលរួមបាបទីស្ត។ ខ្ញុំពីមុនជាកាតូលិក ខ្ញុំចង់ក្លាយជា*នេះ*។ ខ្ញុំចង់ក្លាយជា*នោះ*" វាជាសត្វល្អិតបម្រះខ្ញីកៗ។

140 អូ បំភ្លេចរឿងទាំងមូលហើយចូលមកកាន់ប្រភពទឹក(អាម៉ែន!) អណ្ដូងទឹកជ្រៅ ជាវត្តមានដ៏រស់ជារៀងរហូតរបស់ព្រះគ្រីស្ទ! ខ្ញុំជឿថាទ្រង់ជាប្រភពទឹកជីវិតមិនចេះខ្សោះខ្សោយ។ អ្នកកាន់តែទទួលពីទ្រង់ វាកាន់តែថ្មីស្រស់ និង កាន់តែត្រជាក់ និងកាន់តែប្រសើរ និង កាន់តែផ្អែម។ ខ្ញុំបានបម្រើទ្រង់សាមសិបបីឆ្នាំហើយ ហើយ ថ្ងៃនីមួយៗវាកាន់តែផ្អែមឡើងជាងថ្ងៃមុន។ ខ្ញុំមិនបាន...ទ្រង់មានបន្ទូលថាអ្នកនឹងមិនស្រេកទៀតឡើយបើយើងផឹកទឹកនេះ។ កត់សម្គាល់ថាវាអស្ចារ្យប៉ុណ្ណា។ អូ!

141 អ៊ីស្រាអែលបានធ្វើអ្វីដែលមនុស្សជាច្រើនបានធ្វើសព្វថ្ងៃពួកគេបានចាកចេញ ពីប្រភពទឹករស់ ទៅជីកអាងទឹកមួយសម្រាប់ខ្លួនឯង។

142 ឥឡូវ និយាយពីព្រះគុណមួយភ្លែត អ្វីជាព្រះគុណរបស់ព្រះ។ យើងមានច្បាប់ និង ដោយច្បាប់ "ហើយ បើសិនជាអ្នកមិនវាស់វែងស្ដង់ដានេះ...ខ្ញុំមានដំបងវាស់សាសនា បើអ្នកមិនវាស់វាស្រេចតែវា អ្នកត្រូវតែ អ្នកមិនអាចចូលមក" និងបន្តទៀត។ ប៉ុន្តែព្រះជាម្ចាស់សង្គ្រោះយើងដោយព្រះគុណមិនមែនដោយរង្វាស់រំពាត់ឡើយ។ ឃើញទេ? ប៉ុន្តែព្រះជាម្ចាស់មានបន្ទូលដោយព្រះគុណឥឡូវ ជាអ្វីដែលរឿងនេះកើតឡើង ផឹកពីទ្រង់។ ចេញពីដំបងវាស់នេះ...

143 រអ៊ូរទាំ អ៊ីស្រាអែលរអ៊ូរទាំ។ មើល ទ្រង់មានបន្ទូល "ហើយយើងនឹងមកជួបអ្នកម្ដងទៀត"កត់សម្គាល់ទ្រង់នឹងសាកល្បងពួកគេទ្រង់នឹងយាងជួបគេម្ដងទៀត។

ការរអ៊ូរទាំរបស់អ៊ីស្រាអែល នៅសមុទ្រក្រហម ត្រូវបានហៅឲ្យតាមទ្រង់តាមរយៈ ទឹកកខ្វក់នៅអេស៊ីព្ទឲ្យក្លាយជាមនុស្សមានសេរីភាព។ ពួកគេពីមុនជាទាសករ។ ពួកគេ ត្រូវបានហៅឲ្យចូលមក ដើម្បីក្លាយជាមនុស្សមានសេរីភាព ជាមួយទ្រង់។ ចេញពីសមុទ្រមរណៈ សមុទ្រស្លាប់ សមុទ្រក្រហម ចៀសចេញពីនោះ ទៅវាលរហោស្ថាន ដើម្បីបំបែកពួកគេ និង អ្នកព្យាយាមធ្វើត្រាប់តាមវា ដោយគ្មានការកាត់ស្បែក។

144 អូ នោះជាហេតុបង្កបញ្ហា។ ពួកគេត្រូវរងវិនាសនៅក្នុងវាល...ឬ ត្រូវ—ត្រូវ ក្នុងសមុទ្រ ផារ៉ោន និង ទាហានទ្រង់។ ពួកគេឃើញមនុស្សដើរដោយអំណាច ហួសពីធម្មជាតិ ដូច្នេះពួកគេត្រលប់មកវិញ និង ព្យាយាមធ្វើត្រាប់តាមនោះ ដោយគ្មានបញ្ចូលព្រះពរក្នុងនោះ។ ហើយពេលពួកគេធ្វើ ពួកគេរងវិនាស។ វាជាការប្រៀបធៀបសាច់ឈាម។

145 មនុស្សដែលព្យាយាមធ្វើបែបនោះព្យាយាមត្រាប់តាមអ្វីមួយ នោះគឺគាត់កំពុងធ្វើការប្រៀបធៀបសាច់ឈាមនៃគ្រីស្ទានពិតប្រាកដហើយ។

146 បងប្អូនប្រុសខ្ញុំមកពីឥណ្ឌាដឹងពីរឿងនោះ។ មកជុំវិញបុមបាយ ហើយអ្នកនឹងឃើញមនុស្សនៅទីនោះ។ ហិណ្ឌូ និង ផ្សេងទៀត ដេកលើដែកគោលស្រួចៗ និង លើ...ដើរលើអំបែងកែវ និង—និង ដើរក្នុងភ្លើង ដើម្បីបង្ហាញអ្វីដែលពួកគេអាច ធ្វើ និងអ្វីដូចច្នោះ...នោះគឺជាការត្រាប់ តាមបែបសាច់ឈាម នៃមនុស្សណាម្នាក់ដែលនៅក្នុងព្រៃជាការធ្វើដើម្បីលះបង់សម្រាប់ព្រះរបស់គេ។

147 យើងឃើញការនោះលើជិវិតសាសនា ការត្រាប់តាមសាច់ឈាម មាននរណាម្នាក់ព្យាយាមឲ្យបានដូចជាអ្នកផ្សេង។ មានតែឧទាហរណ៍មួយប៉ុណ្ណោះ អ្នកត្រូវតែមានភាពដូច គឺដូចជាព្រះគ្រីស្ទ ដែលជាព្រះបន្ទូល។ ហើយដូច្នេះពេលព្រះបន្ទូលនៃព្រះមកដល់អ្នក វានឹងមានរបៀបដូចគ្នា។

148 ប៉ុន្តែព្រះជាម្ចាស់ដឹកនាំគេ ទៅកាន់ទឹកដីសន្យា ដោយរបៀបណាក៏ដោយ។ ពួកគេបានឃើញគ្រប់ទាំងអាងទឹកពេលពួកគេចាប់ផ្ដើមឆ្លងកាត់តាម វាលរហោស្ថាននៅក្នុងដំណើររបស់គេឥឡូវបន្ទាប់ពីបែកចេញពួកគេឃើញ ថារាល់ អាងទឹកទាំងអស់ស្ងួត ដល់ពួកគេ។

149 ហើយអ្នកនឹងរកឃើញដូចគ្នា បងប្អូនប្រុស ពេលអ្នកចាប់ផ្ដើមដំណើរនេះ ទៅកាន់ទឹកដីសន្យា។ អ្នកនឹងឃើញទ្វាបិទ។ ដូចជាអ្នកអធិប្បាយតូចមួយបាន

និយាយ អង្គគ្លិខេន ក្រុមជំនុំរបស់គាត់ដេញគាត់ចេញ។ ឃើញ ពេលគាត់ទទួលព្រះវិញ្ញាណបរិសុទ្ធយ៉ាងច្រើន នោះជាពេលបញ្ចប់នៃវាហើយ។

150 ហើយ យើង...ហើយអ៊ីស្រាអែលរកឃើញដូចគ្នា ជាឧទាហរណ៍ ក្នុងដំណើរពួកគេទៅកាន់ទឹកដីសន្យា។ អាងទឹកគឺស្ងួតទាំងអស់។ បាទ ដំណើររបស់ពួកគេដោយស្ដាប់បង្គាប់តាមព្រះបន្ទូលទ្រង់ ដំណើររបស់ពួកគេ ក្នុងអាងទឹក ពួកគេឃើញថាវាស្ងួតហើយ។ ឥឡូវពួកគេរកឃើញអាងទឹក— អាងទឹកមិនអាចពឹងពាក់បាន សម្រាប់ធ្វើដំណើរ។

151 ហើយបើអ្នកនឹងធ្វើដំណើរដោយស្ដាប់បង្គាប់តាមព្រះបន្ទូលព្រះជាម្ចាស់ និងព្យាយាមចូលរួម*នេះ* និង ចូលរួម*នោះ* អ្នកនឹងឃើញថា គ្មានអាងទឹកណានៅក្នុងលោកដែលនឹងអាចជួយបានឡើយ។ គ្មានឡើយ។ អ្នកជាបុគ្គលផ្ទាល់ម្នាក់។ ព្រះជាម្ចាស់ដឹកនាំអ្នកតាមរបៀបទ្រង់ចង់ដឹកនាំអ្នក។ ដូច្នេះ យើងបានរកឃើញអ្វីដូចគ្នាថ្ងៃនេះ និងអាងទាំងអស់ស្ងួត។

152 ប៉ុន្តែ សេចក្ដីសន្យា គឺតែងតែពិត ចំពោះព្រះជាម្ចាស់ ដែលជាអង្គរក្សាសេចក្ដីសន្យារបស់ទ្រង់ ចំពោះរាស្ត្រទ្រង់។ ទ្រង់សន្យានឹងផ្គត់ផ្គង់គេតាមតម្រូវការដូច្នេះទ្រង់ធ្វើបែបនោះ។ ក្នុងពាក់កណ្ដាលនៃភាពទទេ មានអាងស្ងួត សូមគិតពីវានិងអ៊ីស្រាអែលដែលរអ៊ូរទាំ ក្នុងវាលខ្សាច់ ក្នុងការធ្វើដំណើរ! ទ្រង់ត្រាស់ហៅអ្នកដឹកនាំជា-អ្នកបម្រើរបស់ទ្រង់ហោរាម៉ូសេ ចេញទៅម្ខាងនិងបើកប្រភពទឹករស់ ដោយវាយ លើថ្ម ដូច្នេះទ្រង់ជឿជាក់ថាកូនចៅរបស់ទ្រង់មិនត្រូវវិនាសឡើយ។

153 ក្នុងសម័យសព្វថ្ងៃការនោះនិយាយពីព្រះគុណចំពោះខ្ញុំ។ យើងមិនសក្ដិសមទទួល។ របៀបដែលយើងធ្វើរបៀបដែល យើងរស់នៅ យើងមិនសមនឹងទទួលឡើយ។

154 ប៉ុន្តែព្រះជាម្ចាស់ នៅសព្វថ្ងៃនេះ ដូចជានៅព្រឹកនេះ មើលមានមេតូឌីស្ដបាបទីស្ដ ព្រីសប៊ីធីរៀន កាតូលិក និងទាំងអស់ ទ្រង់បានបើកប្រភពទឹកមក។ ហេព្រើរជំពូក១៣បង្ហាញការនេះ ថាទ្រង់នៅដូចម្សិលមិញ ថ្ងៃនេះ និងរៀងរហូតទៅ។ ដូច្នេះវា—វា ធ្វើឲ្យក្លាយជាការពិត យ៉ូហាន ៣:១៦ "ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយដើម្បីឲ្យអស់អ្នក ណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយគឺឲ្យមានជីវិតអស់កល្ប ជានិច្ចវិញ។"

155 ហើយវាត្រូវបានលើកឡើងសម្រាប់កន្សោមហេតុផលព្រោះមនុស្សចេះតែ រអ៊ូរទាំ និងប្រព្រឹត្តិបាបហើយពួកគេត្រូវពស់ចឹកនិង ពួកគេស្លាប់ និង សម្រាប់ការអត់ទោសដល់ពួកគេពីបាបរបស់គេ និង សម្រាប់ព្យាបាលអស់ទាំងជម្ងឺរបស់ពួកគេ។

156 ហើយ នោះជាប្រភពទឹកដដែល ដែលបានបើកឲ្យដល់ពួកយើងសព្វថ្ងៃ សម្រាប់ សេចក្តីសង្គ្រោះ និង ការប្រោសឲ្យជារបស់យើង ការប្រោសឲ្យជាខាងរាងកាយ។ "ព្រោះទ្រង់នៅដូចកាលពីម្សិលមិញ ថ្ងៃនេះ និង រៀងរហូតទៅ។"

157 ហើយ ពេលដែលថ្មនោះត្រូវបានវាយដោយព្រះបន្ទូលសេចក្តីសន្យារបស់ព្រះ ដែលបានបង្គាប់វាបានបញ្ចេញការត្របាញ់ចេញទឹកស្អាត និង សុទ្ធផង មិន—មិនមែនស្អុយនិងកខ្វក់ឡើយប៉ុន្តែជាវត្ថុមានរបស់ព្រះផ្ទាល់។ទឹកសុទ្ធហើយវាសង្គ្រោះ អស់អ្នកដែលផឹក។ ឥឡូវយើងដឹងថា នោះជាការពិត ព្រោះយើងអានវាក្នុងសញ្ញាចាស់ ជាខ្សែរអាត់ថតសម្លេង។

158 ឥឡូវ អ្នកមិនចាំបាច់រុញវា ឬបូមវាឡើយចូលរួមជាមួយវា ចូលរួមការអធិប្បាយរៀនពីរបៀបប្រើវា។ ពួកគេប្រាប់អ្នកពីរបៀបប្រើវានៅទីនោះ ឃើញ "អូ ល្អ អ្នក បើអ្នកទទួលព្រះវិញ្ញាណបរិសុទ្ធ យើងជឿបែបនោះ ប៉ុន្តែដូច្នេះអ្នក—អ្នកធ្វើវារបៀប*នេះ*។"

159 ប៉ុន្តែ អ្នកឃើញទេ គ្មានអ្វីគ្រប់គ្រងវាឡើយ។ អ្នកមិនមែនប្រើព្រះវិញ្ញាណបរិសុទ្ធឡើយ ព្រះវិញ្ញាណបរិសុទ្ធប្រើអ្នកវិញ ឃើញ។ ឃើញទេ អ្នកមិនមែន អ្នកមិនប្រើព្រះវិញ្ញាណបរិសុទ្ធឡើយ ព្រះវិញ្ញាណបរិសុទ្ធជម្រុញអ្នក។ អំណោយទានមិនមែនជាអ្វីអ្នកយកដូចជាកាំបិត និង ប្រដាប់បិតខ្មៅដៃមានខ្មៅដៃក្នុងនោះទេ។ វាជាការរស់នៅភ្ជាប់ខ្លួនអ្នកជាមួយព្រះ និង ធ្វើឲ្យខ្លួនអ្នកចេញមកដោយ របៀបនោះ ដូច្នេះព្រះវិញ្ញាណបរិសុទ្ធអាចប្រើអ្នក។

160 កត់សម្គាល់ ពួកគេមិនត្រូវសប់វា ឬ ទាញវា ឬ ពួកគេមិនចាំបាច់សុំ "ឥឡូវយើងប្រើទឹកនេះរបៀបម៉េច?" ពីព្រោះ ពួកគេដឹងពីរបៀបប្រើវា។ ពួកគេស្រេក។ ពួកគេដឹងនូវអ្វីដែលត្រូវធ្វើជាមួយវា។

161 ហើយ ដូច្នេះ គឺជាមនុស្សប្រុសឬ ស្រី អ្វីក៏ដោយ មិនខ្វល់ថាជាជំនឿសាសនា ឬ និកាយអ្វីដែលគាត់មានទេ។ បើគាត់ស្រេកឃ្លានពីព្រះជាម្ចាស់ គាត់មិនចាំបាច់

រត់ទៅរកការអធិប្បាយទេ ដូចជាបងប្អូនប្រុស អង់ហ្គ្លិកខេនធ្វើ ឬ បងប្អូនប្រុសមកពីអង់គ្លេសធ្វើ កាលពីយប់មិញ ដែលត្រូវទៅវិញ និង ធ្វើការប្រឹក្សាថារបៀបណាត្រលប់ទៅក្រុមមេជំនុំអង់ហ្គ្លិកខេន របៀបគាត់ប្រើអំណោយទានដ៏ធំនេះដែលគាត់មាន និយាយជាភាសារដទៃ និង របៀបដែលគាត់ត្រូវធ្វើ*នេះ*។ គ្រាន់តែចាប់ផ្ដើមពួកគេទាត់គាត់ចេញទៅហើយ។ ឃើញ គាត់ស្រេក ដូច្នេះព្រះជាម្ចាស់ចម្អែតគាត់នោះជាអ្វីទាំងអស់ដែលស្ដីអំពីវា។ វាជាការស្រេកហើយទ្រង់ចម្អែត។

162 អ្នកមិនត្រូវគ្រប់គ្រងទេ នរណាម្នាក់ប្រាប់អ្នកឲ្យធ្វើ ធ្វើវាទៅ។ ព្រះជាម្ចាស់ដឹកនាំមនុស្សម្នាក់ៗក្នុង—របៀបរបស់ទ្រង់ចង់ឲ្យអ្នកធ្វើ។ អ្នកគឺ—មានភាពជាបុគ្គល ខ្លួនអ្នកផ្ទាល់។ អ្នកជាចំណែកនៃព្រះជាម្ចាស់។ គ្មាននរណាអាចជំនួសកន្លែងអ្នកបានឡើយ។ ក៏គ្មានវិធីថាទៅរកនរណាម្នាក់ និង និយាយឥឡូវ ខ្ញុំត្រូវ "ធ្វើ*នេះ*ជាមួយវា" ឬ ខ្ញុំត្រូវ "ធ្វើ*នោះ*ជាមួយវា" ទេ លោក។ ព្រះជាម្ចាស់ប្រើវាតាមរបៀបដែល—ដែលទ្រង់សព្វព្រះទ័យ។ ពេលអ្នកស្រេក អ្នកក៏ចេះផឹកដែរ។

163 ហើយបើអ្នកស្រេកនៅព្រឹកនេះ ផឹកវាចុះ នោះជាអ្វីដែលអ្នកត្រូវធ្វើ។ ព្រះជាម្ចាស់បានប្រទានផ្លូវសម្រាប់អ្នកស្រេក កូនៗដែលស្រេក នឹងត្រូវចូលមករកទ្រង់ផ្ទាល់ដោយសេរី។ ហើយព្រះជាម្ចាស់ប្រទានផ្លូវ ដល់មនុស្សប្រុសស្រីទាំងអស់នៅព្រឹកនេះជាអ្នកដែលឃ្លាន និង ស្រេក។ ប្រហែលមានមនុស្សអង្គុយនៅទីនេះ មិន ទាន់ទទួលសេចក្ដីសង្គ្រោះ។ មានមនុស្សអង្គុយទីនេះ ជាអ្នកជិតនឹងបានសង្គ្រោះ ហើយ។

164 មានមនុស្សនៅទីនេះ អង្គុយទីនេះ ជាសមាជិកក្រុមជំនុំ អ្នកចង់ធ្វើ ប៉ុន្តែអ្នកផឹកពីអាង។ គេនឹងមិនប្រាប់អ្នកពីសេចក្ដីពិតនេះឡើយ។

165 រឿងតែមួយ ត្រូវមក គឺត្រូវយកសេចក្ដីសន្យារបស់ព្រះ និង ចូលមកប្រភពទឹកបន្ទាប់មក ទ្រង់នឹងរំងាប់សេចក្ដីស្រេកឃ្លាន។ "អ្នកដែលផឹកពីប្រភពទឹកនេះ នឹងមិនស្រេកទៀតឡើយ។"

166 កត់សម្គាល់ឥឡូវ ពីរបៀប—របៀបទ្រង់រំដោះមនុស្សរបស់—របស់ទ្រង់ ជាអ្នកទទួលទឹកនោះ ដោយព្រះគុណ និងមិនមែនដោយប្រព័ន្ធ ឬ អាងទឹកនៃការសិក្សាអប់រំឡើយ។ ព្រះទ្រង់កាត់សេចក្ដី ឲ្យឃើញត្រឹមត្រូវចំពោះព្រះបន្ទូលទ្រង់ជាប្រភព ផ្ដល់ជីវិតរស់។ តើប៉ុន្មាននាក់នៅទីនេះ ដែលទទួលជីវិតពេលដែល

អ្នកយកព្រះ បន្ទូល និង ទឹករបស់ទ្រង់ដែល អ្នកទើបតែដឹងថាអ្នកទទួលជីវិត? [ក្រុមជំនុំ និយាយ "អាម៉ែន"—Ed]។

167 ចូរយក ហ្នឹងជាឧទាហរណ៍ ត្រឹមតែជាឧទាហរណ៍មួយ ឬ ពីរ ហើយខ្ញុំនឹងបិទនៅបន្តិចទៀត។ ខ្ញុំ—ខ្ញុំត្រូវតែមានប៊ូតុងនោះនៅកន្លែងណាមួយ។ ប៉ុន្តែសូមចំនាំ។ ខ្ញុំនៅតែបន្តនិយាយប៉ុន្តែខ្ញុំមិនមានន័យយ៉ាងនោះទ្បើយ។ មើល ចូរយកឧទាហរណ៍ ជាមនុស្សមានគ្រួសារ។

168 ចូរយកស្ត្រីនៅអាងទឹកយ៉ាកុប ជាអណ្តូងជីក។ នៅទីនោះនាងអង្គុយនៅទីនោះ។ នោះគឺស្ត្រីគ្រប់គ្នាដឹង មានអាងនៅទីនោះដែលនាងមកដងទឹក។ ហើយនៅជាប់នោះ អណ្តូងដែលនាងឃើញ មានអ្វីតូចមួយឃើញយ៉ាងច្បាស់នៅទីនោះ មានបុរសម្នាក់អង្គុយនៅទីនោះ ជាជនជាតិយូដា។ ហើយ នាងជាសាសន៍សាម៉ារី វាជាក្រុងនៅស៊ូខា។ ហើយយើងឃើញថាបុរសម្នាក់ជនជាតិយូដានេះ និយាយមកជាពាក្យមិនធម្មតា ជាមួយស្ត្រី និយាយ "ចូរយកទឹកមកឲ្យខ្ញុំផង។"

169 នាងនិយាយឥឡូវ "យើងមានការបែងចែក។ វាមិន—មិនសមទេដែលអ្នកនិយាយ សុំខ្ញុំដូច្នេះ អ្នកជាសាសន៍យូដាហើយខ្ញុំជាសាសន៍សាម៉ារី។"

170 គាត់និយាយ "ប៉ុន្តែបើអ្នកដឹងថា នរណាដែលអ្នកកំពុងនិយាយជាមួយ អ្នកអាចសុំខ្ញុំ ទឹកផឹកវិញ ហើយខ្ញុំនឹងឲ្យទឹកដល់អ្នកដែលអ្នកមិនបាច់មកដងនៅអាងទឹកនេះដើម្បីផឹកទៀតទ្បើយ គឺជាអណ្តូងទឹកដែលផុសក្នុងអ្នក" សម្គាល់ពេលនាងឃើញថានេះបង្ហាញពីសេចក្តីពិត!

171 ឥឡូវទីមួយនរណាម្នាក់អាចនិយាយបែបនោះ។ ប៉ុន្តែនាងនិយាយ "អ្នកនិយាយថាថ្វាយបង្គំក្នុងក្រុងយេរូសាទ្បឹមហើយយើងថ្វាយបង្គំនៅលើភ្នំនេះវិញ។"

172 គាត់និយាយ "សេចក្តីសង្គ្រោះគឺមកពីពួកយូដា។ យើងដឹងពីអ្វីដែលយើងជឿ។ ប៉ុន្តែ" និយាយ "ចូរឲ្យខ្ញុំប្រាប់អ្នករឿងមួយ" ក្នុងពាក្យបែបនេះ "មិនទាំងនៅលើភ្នំនេះ ឬក្រុងយេរូសាទ្បឹមទ្បើយ។ មានពេលមកដល់មនុស្សនឹងថ្វាយបង្គំព្រះជាម្ចាស់ដោយវិញ្ញាណនិងសេចក្តីពិតវិញព្រោះព្រះបិតាស្វែងរកបែបនោះ។" គាត់ និយាយ "ទៅហៅប្តីអ្នកមក" មើល នៅទីនេះបង្ហាញពីវា។ នៅទីនេះបង្ហាញអ្វីជាប្រភពទឹក ដែលនាងនៅក្បែរ។ និយាយ "ទៅហៅប្តីនាងមកនៅទីនេះ។"

នាងនិយាយ "ខ្ញុំមិនមានប្ដីទេ្បីយ។"

173 គាត់និយាយ "អ្នកបាននិយាយការពិត។" មើល វាហាក់ដូចជាវាមានភាពផ្ទុយគ្នាច្បាស់ណាស់ ពីអ្វីដែលគាត់សុំនាង និងនិយាយ "ចេញទៅហៅប្ដីមក។"

និយាយ "ខ្ញុំគ្មានប្ដីទេ្បីយ។"

174 និយាយ "អ្នកនិយាយពិតហើយ។" និយាយ "ព្រោះអ្នកមានប្ដីប្រាំហើយហើយ ម្នាក់ដែលអ្នកកំពុងរស់នៅជាមួយឥឡូវក៏មិនមែនជាប្ដីអ្នកដែរ។"

175 មើល ស្ត្រីម្នាក់នោះតើវាខុសពីសង្ឃនៅសម័យនោះយ៉ាងណា! សង្ឃនៅសម័យ នោះបានឃើញអ្វីដូចគ្នា និង និយាយ "នោះជាអារក្ខ គ្រូមើលចិត្ត ឬ—ឬបៀសេបាប់" ឃើញ ពួកគេមិនអាចឃើញ ព្រះបន្ទូលដែលសន្យារឿងនោះ។

176 ប៉ុន្តែស្ត្រីតូចម្នាក់នេះមានការយល់ដឹងខគម្ពីរប្រសើរជាងសង្ឃ។ នាងនិយាយថា "លោក ខ្ញុំដឹងថាលោកជាហោរ៉ា។ យើងមិនមានហោរ៉ាណាម្នាក់ទេ្បីយរយៈពេល៤០០ឆ្នាំ ចាប់តាំងពីម៉ាឡាគីមក។ ប៉ុន្តែ" និយាយ "យើងកំពុងរង់ ចាំម្នាក់ហើយយើងដឹងថា ម្នាក់នោះកំពុងតែមកជាព្រះមេស៊ី។ ហើយពេលទ្រង់យាងមក នេះជាអ្វីដែលទ្រង់នឹងធ្វើ។"

ព្រះយេស៊ូវមានបន្ទូល "គឺខ្ញុំ។" អាម៉ែន។

177 តើអ្នកកត់សម្គាល់ ពេលនាងទុកក្អមចោលនៅអាងទឹកយ៉ាកុប រត់ចុះទៅក្នុងក្រុង ពេញដោយអណ្ដូងទឹកជ្រៅ! នាងបានឃើញថាវាជាការបង្ហាញឲ្យឃើញច្បាស់ថា ត្រូវហើយ ទ្រង់គឺជាអណ្ដូងទឹកនៃជីវិត។ ចូរឲ្យខ្ញុំណែនាំអំពីនាងដល់អ្នក។ នាងចាកចេញពីទីនោះ ពេលទ្រង់បញ្ជាក់ថាទ្រង់ជាព្រះបន្ទូលនៃជីវិត។ នាងទុកវាចោល និង បានរកឃើញថ្មដដែល ដែលត្រូវបានវាយនៅវាលរហោស្ថានត្រូវបានបង្ហាញវត្តមាននាបច្ចុប្បន្នវិញ។

178 ចូរឲ្យខ្ញុំនិយាយ ព្រះជាម្ចាស់ដដែល ដែលនៅថ្ងៃដែលកន្លងទៅ ដែលយើងនិយាយយ៉ាងច្រើនពីទ្រង់ ទ្រង់ក៏មានវត្តមាននៅទីនេះឥឡូវដែរ មិនមែនដោយការយល់បែបទេវសាស្ត្រណាមួយទេ្បីយ ប៉ុន្តែដោយការដឹងផ្ទាល់ខ្លួនបុគ្គល នៃការបង្ហាញឲ្យឃើញថាត្រឹមត្រូវពីទ្រង់ ដែលទ្រង់នឹងអាចចាក់ នៅថ្ងៃចុងក្រោយនេះ ព្រះវិញ្ញាណបរិសុទ្ធលើក្រុមជំនុំ។ ទ្រង់មិនមែនជា"អញពីមុន។" ទ្រង់នៅតែជា "អញ" នាបច្ចុប្បន្នកាល ជានិច្ចរហូត។

179 បន្ទាប់មក អាងទឹកបាត់បង់រសជាតិរបស់វា។ និង គ្រប់គ្នាជាអ្នកធ្លាក់ទៅក្នុងអំណាចព្រះជាម្ចាស់ ដោយការជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ ប្រព័ន្ធនិកាយបាត់រស់ជាតិរបស់ពួកវាហើយ។ អ្នកមិនចាំបាច់ត្រូវ មានកង្កែបកខ្វក់ និង ជីងចក់ និង សត្វស្លាបល្អិតៗ និងអ្វីផ្សេងទៀតឡើយ។ អ្នកកំពុងផឹកពីប្រភពទឹកដែលស្រស់ និង សុទ្ធ ជាព្រះបន្ទូលព្រះ ស្រស់ថ្មីរាល់ម៉ោងក្នុងព្រលឹងអ្នក។ ដូចជាពេលឥឡូវដែរ ពេលព្រះបន្ទូលបើកសម្តែងជាសេចក្តីពិត ភ្លក្ស និង ឃើញថា តើវាមែនឬមិនមែន។

180 ថ្វីបើអាងទឹកបានបម្រើបានល្អបម្រើវេនរបស់វាល្អប៉ុន្តែអ្នកឃើញទេ ប្រភពទឹកនៃជីវិតនៅទីនោះ មិនមែនជាអាងយ៉ាកុបទៀតទេ សម្រាប់ការផឹកខាងវិញ្ញាណ។ អ្វីគេគិតបើគេផឹកពីអណ្តូងនោះហេតុអ្វី វាត្រឹមត្រូវទាំងអស់ទេ ប៉ុន្តែឥឡូវប្រភពទឹកនៃជីវិតផ្ទាល់ មាននៅទីនោះ។

181 ឥឡូវយើងមិនត្រូវការប្រព័ន្ធ និង អង្គការដែលយើងមានទៀតទេ។ យើងនៅចុងបញ្ចប់ហើយ។ ហើយព្រះជាម្ចាស់សន្យា នៅថ្ងៃបញ្ចប់នេះ អ្វីដែលទ្រង់នឹងធ្វើ។ ហើយ យើងឃើញវាបានបំពេញ តាមព្រះបន្ទូល។ យើងឮពីមនុស្សនៃកម្លាំងទាហាន សូមក្រោកឈរ ហើយញាប់ញ័រ និង និយាយពួកគេ "មានអ្វីមួយដែលកំពុង រៀបចំកើតឡើង" យើងមានអារម្មណ៍ដឹងពីព្រះវិញ្ញាណបរិសុទ្ធ ព្រមានយើងថាអ្វីមួយកំពុងរៀបចំកើតឡើង។ យើងឃើញថាអ្វីៗ រៀបចំតាមលំដាប់លំដោយ។ ដូច្នេះ ចាកចេញពីប្រព័ន្ធនិង មកប្រភពទឹកវិញ។ ត្រូវហើយទាំងអស់គ្នា។

182 បម្រើគោលបំណងរបស់វា ប៉ុន្តែឥឡូវនាងនៅមុខទល់នឹងមុខជាមួយប្រភពទឹកផ្ទាល់។

183 ក្នុងគម្ពី យ៉ូហាន៧:៣៧-៣៨ ព្រះយេស៊ូវមានបន្ទូលនៅថ្ងៃចុងក្រោយនៃ ពិធីរោងឧបោសថ (ទ្រង់មានបន្ទូលថាដូចម្តេច?) "បើអ្នកណាស្រេក ឲ្យគេចូលមក និង ផឹកពីខ្ញុំ" ត្រូវក្នុងសំណុំទេវសាស្រ្ត! "បើមនុស្សណាម្នាក់ស្រេកចូរឲ្យមកឯខ្ញុំ និង ផឹកចុះ។ ព្រោះខគម្ពីរបាននិយាយថា ចេញពីខាងក្នុងរបស់លោកនឹងមានទន្លេទឹករស់ចេញមក។"

184 មានប្រភពទឹករស់។ មានប្រភពទឹក ដែលមនុស្សបោះបង់ចោលនាសព្វថ្ងៃ។ ដើម្បីជំនឿសាសនា ពួកគេបានបោះបង់ចោលប្រភពទឹករស់។ ចូរឲ្យខ្ញុំណែនាំអ្នកទៅរកទ្រង់។ ទ្រង់ ចំពោះខ្ញុំ...និង ខ្ញុំនៅកៀក។

185 ទ្រង់ ចំពោះខ្ញុំ គឺជាប្រភពទឹកសង្គ្រោះជីវិតហាកា និង ក្មេងប្រុស ពេលពួកគេ កំពុងតែស្លាប់នៅក្នុងវាលរហោស្ថាន។

186 ខ្ញុំជឿថាទ្រង់ជាថ្មដាក្នុង អេសាយ៣២ ទ្រង់ជាថ្មដា នៅក្នុងទឹកដីដែលសង្រេង។ ទ្រង់ជាជម្រកសម្រាប់ពេលមានព្យុះ។

187 សាការី១៣ ទ្រង់ជាប្រភពទឹកបើកឡើងក្នុងដំណាក់ដាវីឌ សម្រាប់បាប។ ខ្ញុំជឿដល់ទ្រង់ថាជាបែបនោះ។ តើអ្នកមិនជឿទេឬ? [ក្រុមជំនុំនិយាយ "អាម៉ែន"—Ed]។

188 ក្នុងទំនុកតម្កើង៣៦:៩ ទ្រង់ជាប្រភពទឹកជីវិតនៃដាវីឌ។ ទ្រង់ជាទឹកស្ងប់ស្ងាត់នៃដាវីឌ និង ជាវាលស្មៅខៀវខ្ចី។ ទ្រង់ជាទឹកនៅ តាមដងព្រៃកសម្រាប់ដាវីដ។

189 ក្នុងលោកុប្បត្តិ១៧ ទ្រង់ជាដើមទ្រូងថ្នាក់ថ្នមរបស់អ័ប្រាហាំ ជាអេសាដាយ។ ប៉ុន្តែពេលជីវិតរបស់គាត់ទៅឆ្ងាយពីទ្រង់ គាត់នៅតែ...ព្រះមានបន្ទូល។

190 "មនុស្សអាយុមួយរយឆ្នាំ តើការនេះនឹងកើតឡើងរបៀបណា? ខ្ញុំចាស់ហើយប្រពន្ធខ្ញុំចាស់ហើយ តើការនេះនឹងអាចមានជាយ៉ាងណា?"

191 ទ្រង់មានបន្ទូល"យើងជាអេលសាដាយ"ឥឡូវ*អេល* គឺ "The" និង— និង*សាដាយ* គឺ "ទ្រូង" សាដាយជាពហុវចនៈ ដែលមានន័យថា "យើងជាព្រះជាម្ចាស់នៃដើមទ្រូង។"

192 ដូចជាក្មេងដែលមិនស្ទូវស្រួល និង ឈឺ ហើយកម្លាំងចេញពីវាអស់ទៅ វាផ្អែកលើទ្រូងរបស់ម្ដាយ និង ថ្នាក់ថ្នមបង្កើតកម្លាំងជាថ្មី។ ពិតណាស់។ មិនត្រឹមតែ... ពេលវាត្រូវបានថ្នាក់ថ្នម ការថ្នាក់ថ្នមនៅមាននៅឡើយ។ នៅទ្រូងម្ដាយ វាត្រូវបានស្កប់ស្កល់ កាលវាបានទទួលកម្លាំងវិញ។

193 ហើយមនុស្សណាដែលទទួលសេចក្ដីសន្យារបស់ព្រះក្នុងចិត្ត នោះ "សេចក្ដីសន្យានោះគឺសម្រាប់អ្នកដែរ និង កូនចៅរបស់អ្នក និង ពួកអ្នកតំណតទៅ តាមតែព្រះអម្ចាស់ជាព្រះនៃយើងត្រាស់ហៅ" និងដាក់សិទ្ធិពឹងផ្អែកលើនោះចុះ និង បំប៉នកម្លាំងអ្នកត្រលប់វិញ។ក្មេងដែលមិនស្រួលខ្លួនជឿវាណាស់!វាគឺសម្រាប់អ្នកជឿ។

194 ចំពោះកំណាព្យរបស់អ្នកជឿ ខ្ញុំអាចគិតឃើញ ពីចម្រៀងយ៉ាងច្រើនដែលកំណាព្យបានបង្ហាញពីយើង។ នេះជាកំណាព្យខ្លះដែលធ្លាប់និយាយ ទ្រង់...

មានឈាមវិសេសហូរមកលោះបាប
ចេញពីរបួសព្រះអង្គ
ឯមនុស្សមានបាបក៏ចូលទៅក្រាប
ទាំងរួចពីបាបខ្លួនហើយ។

ចោរដែលជិតស្លាប់រីករាយក្នុងការមើលឃើញ
នោះជាប្រភពទឹកក្នុងសម័យរបស់គេ
ខ្ញុំអាច ទោះបើជាចោកទាបដូចជាគាត់
ក៏អាចលាងបាបខ្ញុំទាំងអស់ចេញដែរ។

ហើយតាំងពីនោះដោយជំនឿខ្ញុំឃើញទន្លេ
របួសរបស់ទ្រង់បានបំពេញ
សេចក្ដីស្រឡាញ់ប្រោសលោះបានក្លាយជារឿងរបស់ខ្ញុំ
នឹងនៅរហូតលុះខ្ញុំស្លាប់។

195 សម្រាប់ខ្ញុំ ទ្រង់គឺជាទឹកនៃព្រះបន្ទូលនៃការញែក ដែលបំបែកអ្នកចេញពីគ្រប់ អ្វីដែលទាស់នឹងព្រះបន្ទូលទ្រង់។ នោះជាប្រភពទឹក ខ្ញុំជឿថាគឺជាទ្រង់។ ហ្នឹងហើយ។ នោះ វាជាទឹកដែលញែកខ្ញុំចេញពីអាងទឹកបង្កើតដោយមនុស្ស ឲ្យទៅឯប្រភពទឹករស់។ អូ សម្លាញ់ ខ្ញុំអាច...អ្នកអាចបន្តទៅទៀត ជាមួយអ្វីដែល—ដែលទ្រង់មានចំពោះយើង។ ទ្រង់ជាអាល់ហ្វា អូមេហ្គា។ ទ្រង់ជាចំណាប់ផ្ដើម ទ្រង់ជាទីបញ្ចប់។ ទ្រង់ឥឡូវជាទ្រង់ដែលនៅពីមុនដែរ ដែលជា និង ត្រូវមក។ ទ្រង់ជាឫសគល់ និង ជាកូនចៅដាវីឌ។ ទ្រង់ជាតារាពេលព្រឹក។ ទ្រង់ជាអ្វីទាំងអស់របស់ខ្ញុំនៅក្នុងគ្រប់អ្វីទាំងអស់។

196 ហើយ បងប្អូនប្រុស ស្រី បើអ្នកមិនមាន—មាន...ជាការផឹកពីអាងតូចដែលមនុស្សធ្វើពេញមួយជីវិតរបស់អ្នកហេតុអ្វីបានជាព្រឹកនេះមិនបោះបង់ អាងនោះ ហើយ មករកប្រភពទឹកនោះវិញ។

197 ចូរឲ្យយើងឱនក្បាលមួយភ្លែត។ ជាមួយក្បាលអ្នកនៅឱន...[បងប្អូនស្រីម្នាក់កំពុងច្រៀងជាភាសាដទៃ។ ចំនុចទទេលើខ្សែអាត់។ មានម្នាក់ជាអ្នកបកប្រែ—Ed]...ចំពោះគំនិតរបស់ខ្ញុំ ជាការហៅអាសនា។ មានប៉ុន្មាននាក់ឥឡូវ?

198 ខ្ញុំ—ខ្ញុំពីមុនភ័យ ខ្ញុំ—ខ្ញុំទុកអ្នកនៅយូពេក ធ្វើឲ្យខ្ញុំកាត់សារជាចម្រៀកៗ។ ប៉ុន្តែខ្ញុំជឿថាព្រះវិញ្ញាណបរិសុទ្ធមានព្រះទ័យ ចង់ឲ្យអ្នកទទួលអ្វីដែលខ្ញុំនិយាយ។ មើល គ្មានអ្វីសំខាន់ជាងថ្ងៃនេះ នៅជាមួយព្រះជាម្ចាស់នោះទេ មើល អាហារពេលល្ងាចរបស់យើង នៅកន្លែងណាក៏ដោយ អ្វីក៏ដោយ។ ព្រះអម្ចាស់គង់នៅទីនេះ។ ឥឡូវ ខ្ញុំបានឮរឿងនោះដែលធ្លាប់មានក្នុងជីវិតខ្ញុំ តាំងពីពេលនេះមក។

199 ឥឡូវ តើ...អ្នកទាំងអស់គ្នានៅទីនេះ មិនថា "ប៉ុន្មានទេ។" អ្នកទាំងអស់គ្នានៅទីនេះចង់ផឹកពីនោះចូរក្រោកឈរមួយនាទីសម្រាប់ការអធិស្ឋាន។ សូមព្រះអម្ចាស់ប្រទានពរអ្នក។

200 ឥឡូវ មានប៉ុន្មាននាក់នៅទីនេះ នោះ—នោះឈរនៅនាបច្ចុប្បន្ន នឹងនិយាយដោយការលើកដៃដូច*នេះ* "ព្រះជាម្ចាស់ ធ្វើចលនាក្នុងខ្ញុំ បំពេញខ្ញុំ ឲ្យខ្ញុំផឹកពីប្រភពទឹកនេះ។ ហើយខ្ញុំមិនបានធ្វើអ្វីត្រូវឡើយ ប៉ុន្តែទូលបង្គំ—ទូលបង្គំចង់ឲ្យទ្រង់អត់ទោសឲ្យទូលបង្គំចំពោះរឿងនេះ។ ទូលបង្គំចង់ឲ្យទ្រង់លាងសម្អាតបាបរបស់ ទូលបង្គំ។ និងអនុញ្ញាត—អនុញ្ញាត—អនុញ្ញាតទូលបង្គំ ពីថ្ងៃនេះទៅ ត្រឹមជា..."? ត្រឹមតែមើល! ខ្ញុំអើយ!

មានឈាមវិសេសហូរមកលោះបាប
ចេញពីរប្តួសព្រះអង្គ
ឯមនុស្សមានបាបក៏ចូលទៅក្រាប
ទាំងរួចពីបាបខ្លួនហើយ។
ទាំងរួចពីបាបខ្លួនហើយ
ទាំងរួចពីបាបខ្លួនហើយ
ឯមនុស្សមានបាបក៏ចូលទៅក្រាប
ទាំងរួចពីបាបខ្លួនហើយ។

201 ឥឡូវគឺថា អ្នកជាអ្នកជឿគ្រីស្ទាន អ្នកទទួលព្រះគ្រីស្ទជាព្រះសង្គ្រោះផ្ទាល់ខ្លួន ប៉ុន្តែអ្នកមិនទាន់មាននៅឡើយ...ឥឡូវបើអ្នកមិនមាន ប្រភពទឹកនោះ។ អង្គតែមួយដែលខ្ញុំស្គាល់គឺជាប្រភពទឹកពីសសៃអ៊ីម៉ាញូអែល។ ឥឡូវហើយបើអ្នកជាច្រើននៅទីនេះ...

202 វាដូចជា ខ្ញុំកំពុងនិយាយកាលពីយប់មុនអំពីរឿង ឥន្ទ្រីតូចដើរជាមួយកូនមាន់ក្នុងចំការទំពាំងបាយជូ។ គាត់មិនដឹងពីអ្វីនៃកូនមាន់ឡើយ ប៉ុន្តែដឹងថាមានអ្វី មួយ

នៃខ្លួនខុសពីកូនមាន់។ បន្ទាប់មកមេរបស់វាមករកវា ហើយមេស្រែកពីលើ។ វាជាការហៅរបស់ឥន្ទ្រី។ ឃើញវាត្រូវតែក្លាយជាឥន្ទ្រីពីដំបូង បើមិនដូច្នោះវាមិន អាចស្គាល់ការហៅនោះឡើយ។ ឃើញ វា...

203 ត្រូវតែជាអ្វីនៅត្រង់នោះ ដែលមានពន្លក បើមិនដូចច្នោះវាមិនអាចបង្កើតជីវិតបានឡើយ។ ហើយបើសិនជាគ្រាប់ពូជព្រះបន្ទូលព្រះ នៅក្នុងខ្លួនអ្នក ព្រះវិញ្ញាណបរិសុទ្ធគង់ទីនេះឥឡូវនឹងបណ្តុះពន្លក និង នាំវានូវការពិតដល់អ្នក។

204 តើប៉ុន្មាននាក់នៅក្នុងនេះមិនទាន់ទទួលការជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធតើអាចលើកដៃបានទេ? ទាំងអស់ជុំវិញគ្រប់កន្លែង ជាភាពស្មោះត្រង់ពិតៗ បើអ្នកមិនទាន់ទទួលព្រះវិញ្ញាណបរិសុទ្ធហើយ អ្នកចង់បាន សូមលើកដៃ។ អ្នកនៅទីណាក៏ដោយសូមលើកដៃអ្នកឡើង។ អ្នកនៅទីណាក៏ដោយនៅបន្តលើកដៃមួយភ្លែត។

205 ឥឡូវខ្ញុំចង់ឲ្យអ្នកឈរជុំវិញ មើលពួកគេខ្ញុំចង់ឲ្យ នរណាម្នាក់ដាក់ដៃលើគេ។

206 ខ្ញុំជឿឥឡូវថាព្រះវិញ្ញាណបរិសុទ្ធ នឹងបំពេញគ្រប់គ្នានៃអ្នកដែលចង់បានវា។ ឥឡូវកុំគិតពីអាហារនៅកន្លែងលក់។ សូមគិតពីអាហារនៅទីនេះ។ នេះជាអង្គមួយ។ នេះជាជីវិត។ ឃើញ នេះជាជីវិត។

207 ឥឡូវសូមបែរទៅគ្នាទៅវិញទៅមក និងដាក់ដៃលើគ្នាទៅវិញទៅមក។ "ហើយពួកគេដាក់ដៃពួកគេលើគ្នា!" ឥឡូវ ខ្ញុំចង់ឲ្យអ្នកអធិស្ឋានដល់អ្នកដែលដាក់ដៃលើ...

208 ឥឡូវកុំគិតពីការចេញទៅក្រៅ។ កុំគិតពីអ្វីផ្សេងទៀត។ គិតតែឥឡូវព្រះវិញ្ញាណបរិសុទ្ធនៅទីនេះដើម្បីបំពេញបុគ្គលម្នាក់ៗ។ បើកចិត្តបូមទឹកអាងចេញ ហើយ និយាយ "ឱប្រភពទឹករស់ សូមមកឯខ្ញុំ។ បំពេញខ្ញុំ ឱព្រះអម្ចាស់ជាព្រះ ដែលមាន ដោយសេចក្តីល្អ និង ក្តីមេត្តា។"

209 ព្រះអម្ចាស់យេស៊ូវ ដែលជាប្រភពទឹកមិនចេះខ្សោះខ្សោយ! ទូលបង្គំអធិស្ឋានព្រះជាម្ចាស់ ដែលទ្រង់នឹងបំពេញគេម្នាក់ៗ។ សូមឲ្យព្រះវិញ្ញាណបរិសុទ្ធធ្លាក់មកទីនេះ។ ទូលបង្គំអធិស្ឋាន ព្រះជាម្ចាស់ ដែលយើងនឹងបំភ្លេចអ្វីផ្សេងទៀត នោះព្រះវិញ្ញាណបរិសុទ្ធនឹងធ្លាក់ចូលក្នុងគំនិតទូលបង្គំ ឥឡូវ នឹងប្រទានឲ្យយើងនូវទឹករស់ ដោយឥតគិតថ្លៃ ពីគ្រប់កន្លែង។ សូមទទួលព្រម ឱព្រះជាម្ចាស់អើយ។ កាល

—នៅតែបន្តអធិស្ឋាន និង ច្រៀង លាយបញ្ចូលគ្នា ព្រះអម្ចាស់ ដឹងថាជាវត្តមានទ្រង់ ជាវត្តមានភាពជាព្រះរបស់ទ្រង់ ទូលបង្គំចង់ចូលមកប្រភពទឹក។ ទូលបង្គំចង់បានការជ្រមុជដ៏ពិតជាមួយព្រះវិញ្ញាណបរិសុទ្ធ។ ព្រះអម្ចាស់ មនុស្សទាំងនេះអធិស្ឋានដើម្បីការនោះ។ ទូលបង្គំអធិស្ឋាន នេះជាពេលត្រឹមត្រូវ ដែលពួកគេនឹងត្រូវបានបំពេញដោយសេចក្ដីល្អនៃព្រះជាម្ចាស់។ សូមទទួលព្រម ឱព្រះជាម្ចាស់។ សូមទ្រង់ស្ដាប់សេចក្ដីអធិស្ឋានរបស់កូន។ សូមទ្រង់យាងមកលើពួកគេ សូមឲ្យចេស្ដារបស់ព្រះជាម្ចាស់ និង ព្រះវិញ្ញាណបរិសុទ្ធ ធ្លាក់លើពួកគេ។ សូមអនុញ្ញាតិព្រះជាម្ចាស់អើយ។

210 អូ អរព្រះគុណទ្រង់សម្រាប់ការធ្វើឲ្យក្លាយជាស្រស់ថ្លា សម្រាប់វត្តមានព្រះដ៏មានចេស្ដានៃស្ថានសួគ៌ ដែលតាំងមានក្នុងគំនិតរបស់ទូលបង្គំ! នៅពេលថ្ងៃត្រង់ព្រះអម្ចាស់ សូមចម្អែតទូលបង្គំ! ព្រះអម្ចាស់ ទូលបង្គំត្រូវការអាហារមកពីតុរបស់ទ្រង់។ សូមចម្អែតទូលបង្គំគ្រប់គ្នា ព្រះអម្ចាស់ នាឥឡូវ។ សូមចម្អែតទូលបង្គំដោយព្រះវិញ្ញាណបរិសុទ្ធ ក្នុងជីវិតរបស់ទូលបង្គំ។ ព្រលឹងរបស់ទូលបង្គំ ដែលស្រេកឃ្លានការអធិប្បាយគឺស្រេកខ្លាំងណាស់។ ដូចទ្រង់មានបន្ទូលតាមរយៈការបកស្រាយដោយបទចម្រៀង "វានឹងបានចាក់ទឹកលើដីដែលស្ងួត។" ចូរឲ្យវាកើតឡើង ព្រះអម្ចាស់អើយ។ សូមឲ្យព្រះបន្ទូលទ្រង់បើកបង្ហាញឲ្យឃើញក្នុងចិត្តរបស់កូនទ្រង់ "ទឹកលើដីស្ងួត" សូមឲ្យវាកើតឡើងព្រះអម្ចាស់។សូមឲ្យព្រះបន្ទូលទ្រង់ បានបើកសម្ដែងនៅក្នុងចិត្តរបស់កូនទ្រង់ "ទឹកលើដីស្ងួត"។ ព្រះដ៏នៅអស់កល្ប សូមស្ដាប់សេចក្ដីអធិស្ឋានរបស់អ្នកបម្រើទ្រង់ និង ន្រទានឲ្យទូលបង្គំ នូវព្រះពរ។ អាមែន។

អូ ខ្ញុំស្រឡាញ់ព្រះយេ យ៉ាងណា…

211 សូម នៅតែបន្តសរសើតម្កើងទ្រង់ឥឡូវ។ ស្វែងរកព្រះវិញ្ញាណបរិសុទ្ធនៅទីនេះ។ បើអ្នកមិនទទួលវា វាជាកំហុសរបស់អ្នក។

ខ្ញុំស្រឡាញ់ព្រះយេស៊ូវយ៉ាងណា

"ស្រឡាញ់ទ្រង់ជាងអស់ទាំងសេចក្ដីនេះ?"

…ស្រឡាញ់ព្រះយេស៊ូវយ៉ាងណា
ពីព្រោះទ្រង់ស្រឡាញ់ខ្ញុំមុន។

អូ ខ្ញុំស្រឡាញ់...(សូមសរសើរព្រះ!)
អូ ខ្ញុំស្រឡាញ់...(តើមានអ្វីបើទ្រង់យាងមក...?...-ment?)
អូ ខ្ញុំស្រឡាញ់ព្រះយេស៊ូវណាស់
ព្រោះទ្រង់ស្រឡាញ់ខ្ញុំជាមុន។

ខ្ញុំមិនបោះបង់ទ្រង់ឡើយ
ខ្ញុំមិនបោះបង់ទ្រង់ឡើយ
ខ្ញុំមិនបោះបង់ទ្រង់ឡើយ
ព្រោះទ្រង់ស្រឡាញ់ខ្ញុំជាមុន។

អស្ចារ្យ អស្ចារ្យ ព្រះយេស៊ូវសម្រាប់ខ្ញុំ
ជាអ្នកប្រឹក្សាជាអម្ចាស់សុខសាន្តទ្រង់ជាព្រះមានចេស្តា
អូសូមសង្គ្រោះទូលបង្គំសូមរក្សាទូលបង្គំចេញពីបាបនិង
អាម៉ាស់
អ្នករំដោះខ្ញុំទ្រង់អស្ចារ្យ សូមសើសើរដល់ទ្រង់...

212 ចូរច្រៀងចំពោះទ្រង់ឥឡូវ!

អស្ចារ្យ អស្ចារ្យ ព្រះយេស៊ូវសម្រាប់ខ្ញុំ
ជាអ្នកប្រឹក្សាជាអម្ចាស់សុខសាន្តទ្រង់ជាព្រះមានចេស្តា
អូសូមសង្គ្រោះទូលបង្គំសូមរក្សាទូលបង្គំចេញពីបាប និងក្តី
អាម៉ាស់
អ្នករំដោះខ្ញុំទ្រង់អស្ចារ្យ សូមសើសើរដល់នាមទ្រង់!

213 អស់ទាំងអារម្មណ៍ និយាយ "អាម៉ែន។" [ក្រុមជំនុំនិយាយ "អាម៉ែន"—Ed.]។ អូ ហាលេលូយ៉ា! ខ្ញុំឃើញមនុស្សចូលមក ឥឡូវ ជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ។

ពីដើមបាត់បង់ ឥឡូវឃើញវិញ រំដោះពីការកាត់ទោស
ព្រះយេស៊ូវប្រទានសេរីភាព និង ពេញដោយសេចក្តីសង្គ្រោះ
សង្គ្រោះខ្ញុំ រក្សាខ្ញុំរួចពីបាប និង ក្តីអាម៉ាស់
ព្រះសង្គ្រោះខ្ញុំអស្ចារ្យ សូមសរសើរនាមទ្រង់។

ចូរលើកដៃយើងឡើងហើយសរសើរឥឡូវ សរ....

អូ អស្ចារ្យ អស្ចារ្យ ព្រះយេស៊ូវសម្រាប់ខ្ញុំ
ជាអ្នកប្រឹក្សាជាអម្ចាស់សុខសាន្តទ្រង់ជាព្រះមានចេស្ដា
អូ សូមសង្គ្រោះទូលបង្គំ សូមរក្សាទូលបង្គំចេញពីបាប និង
  ក្ដីអាម៉ាស់
ទ្រង់អស្ចារ្យ អ្នករំដោះខ្ញុំ សូមសើសើរដល់នាមទ្រង់!

214 តើអ្នកស្រឡាញ់ទ្រង់ទេ?[ក្រុមជំនុំនិយាយ"អាម៉ែន!"—Ed.]អូអស្ចារ្យ សរសើរដល់ប្រភពទឹកពេញដោយលោហិត ដែលមនុស្សបាបអស់ការភ័យខ្លាចពីមនុស្សទាំងការកាត់ទោស គឺមានសេរីភាពក្នុងទ្រង់។ ហាលេលូយ៉ា! អូ ខ្ញុំអើយ នោះគឺអស្ចារ្យ!

215 ឥឡូវ កាលយើងកំពុងច្រៀងបទនោះម្ដងទៀត សូមឲ្យ អ្នកមេតូឌីស្ត បាបទីស្ត កាតូលិក ព្រីសប៊ីធីរៀន អ្វីក៏ដោយ ពេលយើងច្រៀងថា "អស្ចារ្យ ព្រះយេស៊ូវសម្រាប់ខ្ញុំ"សូមបែរនិង ចាប់ដៃជាមួយគ្នា សូមឲ្យមានការរួមបញ្ចូលដូចកាលពីមុនយ៉ាងល្អ។ អ្នកដឹងទេខ្ញុំនោះជាអ្វីដែលខ្ញុំចូលចិត្ត។ បន្តសូមច្រៀងឥឡូវ ពេលយើងធ្វើបែបនេះ។

អូ អស្ចារ្យ អស្ចារ្យព្រះយេស៊ូវសម្រាប់ខ្ញុំ

216 ប្រងប្អូនប្រុស ដេមូស សាកឌីរៀន និយាយទៅកាន់បង ប្រុសប្រានហាំ "បងប្រុសប្រានហាំខ្ញុំទើបទទួលបានពាក្យរបស់លោកប្រធានាធិបតី ចនសាន់ គាត់រត់ទៅមន្ទីរពេទ្យដោយជម្ងឺគាំងបេះដូងសូមឲ្យយើងអធិស្ឋានដល់លោក និង សម្រាប់ប្រជាជាតិយើងៗ" បងប្អូនប្រុសពិភាក្សារឿងនេះ។ មានមនុស្សម្នាក់និយាយ "សូមចាំបន្ដិច"—Ed.]។

អស្ចារ្យ ព្រះយេស៊ូវ (ត្រូវហើយ)
អូ ជាអ្នកប្រឹក្សា ជាអម្ចាស់សុខសាន្ត

217 ប្រងប្អូនប្រុស សេកឌីរៀន និយាយម្ដងទៀតពីបងប្អូនប្រុសប្រានហាំ "សូមអត់ទោសឲ្យខ្ញុំ សូមអធ្យាស្រ័យម្ដងទៀត តើអ្នកចង់ចុះទៅមួយនាទីទេ?" បងប្អូនប្រុស អឹល ព្រីកខិត ដឹកនាំសន្និបាតក្នុងចម្រៀង *អស្ចារ្យ* ខ្សែរអាត់ទទេ។ ក្រុម ជំនុំច្រៀងបទ *មានទន្លេជីវិត*។ ខ្សែរអាត់ទទេម្ដងទៀត—Ed.]។

ព្រះគម្ពីរនិយាយ "អធិស្ឋានសម្រាប់អ្នកកាន់អំណាច។"

218 ព្រះវរបិតាស្ថានសួគ៌របស់យើង យើងកំពុងឈរ ដោយចិត្តយើងត្រូវការ ប្តូរផ្តាច់សម្រាប់អ្នកដឹកនាំប្រជាជាតិ ប្រធានាធិបតីរបស់យើង។ គាត់មិនអាចដឹង ព្រះអម្ចាស់ ប៉ុន្តែទ្រង់ជ្រាប។ ទូលបង្គំអធិស្ឋាន សម្រាប់បងប្អូនប្រុសចនសាន់ ដែលគាត់អះអាងថា ជាអ្នកជឿដល់ទ្រង់។ និង ព្រះវរបិតា ជំងឺគាំងបេះដូង យើងដឹងថា វាបានវាយគាត់។ ទូលបង្គំអធិស្ឋាន ព្រះជាម្ចាស់ រំដោះជីវិតលោក។ ទូលបង្គំកំពុងស្ថិតនៅ—ស្ថានភាពមានវិបត្តិឥឡូវ។ ហើយសូមឲ្យព្រះវិញ្ញាណទ្រង់យាងមកលើគាត់ ព្រះអម្ចាស់។ ហើយ ឥឡូវ នៅក្នុងមន្ទីរពេទ្យ ឬ នៅកន្លែងណាដែលគាត់នៅ ហើយ សូមវិញ្ញាណរបស់ទ្រង់យាងចុះមកមន្ទីពេទ្យវ៉លធឺរីដ និង ប៉ះរាងកាយរបស់ទ្រង់ រំដោះជីវិតគាត់។ ព្រះអម្ចាស់ មនុស្សនោះកំពុងស្ថិតក្នុងសម្ពាធមានសម្ពាធជាងអ្វីដែលយើងយល់។ ដូច្នេះយើងអធិស្ឋាន ព្រះជាម្ចាស់ ដូចជាអ្នកជឿ និង ជាផ្នែកមួយនៃជាតិ ទូលបង្គំអធិស្ឋានសម្រាប់អ្នកដឹកនាំដែលទ្រង់នឹងទទួលគាត់ពន្យាជីវិតក្នុងម៉ោងដ៏សំខាន់នេះក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

**អាងទឹកប្រេះបែក** KHM65-0123

(Broken Cisterns)

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះត្រូវបានចែកចាយនៅព្រឹក ថ្ងៃសៅរ៍ ថ្ងៃទី 23 មករា 1965 នៅក្រុមធុរៈកិច្ចដំណឹងល្អអន្តរជាតិ Ramada Inn, Phoenix, Arizona, U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយ ការផ្ទៀងផ្ទាត់យ៉ាង ត្រឹមត្រូវ ជាសារសម្លេង ចេញពីខ្សែរអាត់ថត ចម្លង និង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរ នេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក ។

KHMER

©2019 VGR, ALL RIGHTS RESERVED

Voice Of God Recordings
P.O. Box 950, Jeffersonville, Indiana 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវែបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG